**OMI0019**

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ចាន់ សឿន ភេទប្រុស អាយុ៥៨ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ “យោធា”

## រស់នៅភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

## ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ផាត កុសល

## ០១:៤០:៤៦

## ៤៦ទំព័រ

កុសលៈ ពូមានធ្វើដំឡូងទេ?

សឿនៈ អត់បានធ្វើនឹងគេផង ។

កុសលៈ គ្រួសារខ្ញុំពូគាត់ធ្វើដំឡូងប៉ុន្មាន១០ហិចតាដែរ តែវាលើទូលគ្រាន់បើបន្តិច ។

សឿនៈ គ្រាន់បើហើយ ទួលនេះក្រុមហ៊ុនគេធ្វើ ខាងកើតភូមិចំដីទំនាបលិចទឹកអស់រលីង រលួយដើម រលួយទាំងឫស ។

កុសលៈ ដាំទឹកហើយពិបាកណាស់ ។

សឿនៈ ពិបាក បូករងហើយ យើងគប់រងដែរ តែគប់ទៅវាមិនមែន គប់បាននៅដូចយើងអត់ធ្វើអីណា ដល់ពេលនេះវាចេះតែភ្លៀងច្រោះៗរលាយរងទៅ ដំឡូងដាំទឹកដដែល ។

កុសលៈ អត់កើត មើមក៏មិនច្រើនដែរ ។

សឿនៈ វាមិនមានទាំងមើមទៀត ស្អុយអស់ ក្រហមអស់ ។

កុសលៈ ពូខ្ញុំ១០ហាត់ដែរ ធ្វើលើទួលគ្រាន់បើបន្តិច ។

សឿនៈ បានទួលមិនអីទេ ។

កុសលៈ អីចឹងខ្ញុំចុះមកថ្ងៃនេះខ្ញុំបង្រៀនបាន២ឆ្នាំហើយ ខ្ញុំបង្រៀននៅខាងសកលវិទ្យាល័យភ្នំពេញ ហើយគោលបំណងនៃការសិក្សា គឺខ្ញុំគិតថា ចុះស្ទាបស្ទង់គ្រប់ភូមិនៅអន្លង់វែងនៅខាងម៉ាឡៃ តំបន់ដែលធ្លាប់ជាអតីត ហើយគោលបំណងទី១ គឺសំខាន់បំផុតខ្ញុំចាប់អារម្មណ៍រឿងបញ្ហាផ្សះផ្សារជាតិ ធ្វើយ៉ាងណាឲ្យប្រទេសយើងមានសន្តិភាព កុំឲ្យមានបែកបាក់តទៅមុខទៀត ហ្នឹងគោលដៅនៃការស្ទាបស្ទង់មតិ គឺអីចឹងឯង ហើយខ្ញុំគិតថាគ្មានអ្នកណាដឹងជាងជនទាន់លោកពូធ្លាប់ឆ្លងកាត់មក លោកពូដឹងស្រាប់ហើយសព្វថ្ងៃមាន

ជម្លោះជាមួយថៃទៀត បញ្ហាអ្នកណាដែលប្រឈមមុខរាល់ថ្ងៃ គឺពួកអតីតហ្នឹង ហើយដែលប្រឈមមុខការពារព្រំដែន ខ្លួនខ្ញុំផ្ទាល់ចុះមកបាន៣-៤អាទិត្យ ហើយនេះ ទី៤ចុះធ្វើនេះពី២ខែទៅ៦ខែ ហើយគ្នា៣នាក់ ស្រីម្នាក់ឈឺបាត់ហើយ ចុះមកអត់រួច នៅតែប្រុសៗ២នាក់(សើច) ។ អ៊ីចឹងលោកពូឈ្មោះអីដែរ? ឈ្មោះពេញ? ខ្ញុំសរសេរ ។

សឿនៈ ចាន់ សឿន ។

កុសលៈ សឿ ។

សឿនៈ បាទ ។

កុសលៈ មានឈ្មោះអីផ្សេងទេ? មានឈ្មោះហៅផ្សេង?

សឿនៈ អត់ទេ ហៅតែប៉ុណ្ណឹង ។

កុសលៈ លោកពូចាំថ្ងៃខែកំណើតទេ?

សឿនៈ អត់ទេ ចាំតែឆ្នាំកំណើត ។

កុសលៈ ថ្ងៃនេះថ្ងៃទីប៉ុន្មានហើយ? ថ្ងៃទី៤? ថ្ងៃទីប៉ុន្មានខ្ញុំភ្លេចទៅ ថ្ងៃទី៥ ឬទី៤? ថ្ងៃទី៥ ខែ៩ ២០១១ ។ យើងធ្វើនៅភូមិនៅភូមិដើមភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ថ្ងៃខែកំណើតលោកពូសឿន កើតថ្ងៃទីប៉ុន្មាន ឆ្នាំណា?

សឿនៈ អត់ចាំថ្ងៃកើត ចាំតែឆ្នាំ ។

កុសលៈ កើតឆ្នាំប៉ុន្មាន?

សឿនៈ កើតឆ្នាំ១៩៥៣ ។

កុសលៈ ខែអត់ចាំទេ?

សឿនៈ ខែ១២ អត់ចាំថ្ងៃ ។

កុសលៈ អ៊ីចឹងអាយុប៉ុន្មានឆ្នាំហើយលោកពូ? ៥៧-៥៨ហើយ ៥៨ឆ្នាំហើយឆ្នាំនេះ ។ ទីកន្លែងភូមិកំណើតចាំទេពូ?

សឿនៈ ទីលំនៅចាស់ខ្ញុំនៅឆ្ងាយណាស់ ។

កុសលៈ នៅភូមិអី?

សឿនៈ នៅភូមិ

ប្រពន្ធៈ ភ្លេចភូមិខ្លួនឯងហើយ ។

សឿនៈ វង្វេងហើយ ។

កុសលៈ វង្វេង ។

សឿនៈ នៅភូមិហាងខ្លួន ។

កុសលៈ	ចាំស្រុកទេ?
សឿនៈ	ស្រុកហ្នឹងដែរ ។
កុសលៈ	ស្រុកអី
សឿនៈ	ស្រុកហាងខ្វសួន ប៉ុន្តែខេត្ត ។
កុសលៈ	ខេត្តតាកែវ?
សឿនៈ	ខេត្តស្ទឹងត្រែង ។
កុសលៈ	ឆ្ងាយផង ។
សឿនៈ	បាទ ។
កុសលៈ	ស្រុកអីគេពូ ស្រុកអី ចាំស្រុកទេ?
សឿនៈ	ស្រុកហាងខ្វសួន ពាក្យលាវ ។
កុសលៈ	ហាងខ្វសួន ខ្ញុំមិនដែលលឺទេ ឃុំក៏អីចឹងដែរ?
សឿនៈ	បាទ ។
កុសលៈ	ពាក្យលាវ?
សឿនៈ	លាវ ។
កុសលៈ	លោកពូចាំដូចថា ព្រឹត្តិការណ៍ពេលដែលសម្តេចឪត្រូវគេធ្វើរដ្ឋប្រហារទម្លាក់ពូនៅ ចាំទេ?
សឿនៈ	ឆ្នាំណា អូ នៅតូចនៅស្ទើរណាស់ ។
កុសលៈ	នៅស្ទើរ?
សឿនៈ	បាទ ។ នៅវ័យ ។
កុសលៈ	ឆ្នាំ៧០?
សឿនៈ	ដឹងតែ៧០ហើយ ថ្ងៃណាមិនដឹងទេ ។
កុសលៈ	១៨ មិនា ឆ្នាំ១៩៧០ ពូធ្លាប់លឺទេ?
សឿនៈ	លឺ ។
កុសលៈ	ហើយសភាពការណ៍ក្នុងភូមិយ៉ាងម៉េចដែរ នៅចាំទេពេលហ្នឹង?
សឿនៈ	កាលស្រុករដ្ឋប្រហារគិតទៅស្រុកខ្ញុំ តំបន់ស្វ័យតមុនគេ កាលហ្នឹងជំនាន់វៀតណាម ចូលឆ្នាំ១៩៧៣កើតគេហៅ ។
កុសលៈ	រណសិរ្ស?
សឿនៈ	រណសិរ្សហ្នឹងឯង ។

កុសលៈ	វណ្ណសិរីឆ្នាំ៧៣ អីចឹងស្រុកភូមិចាប់ផ្ដើមមានការដូចថា ធ្វើសហករណ៍ធ្វើរួមនៅ៧៣ ? វណ្ណសិរីកាន់កាប់នៅ?

សឿនៈ	៧៣ ខ្ញុំអត់នេះផង ខ្ញុំមកធ្វើជាយោធាហើយ ។

កុសលៈ	៧៣ ពូចូលជាយោធាហើយ?

សឿនៈ	បាទ ។

កុសលៈ	ពេលហ្នឹងចូលបដិវត្តន៍អីចឹង?

សឿនៈ	គេហៅចូលបដិវត្តន៍ ។

កុសលៈ	ពូចូលឆ្នាំ៧៣ហ្នឹងតែម្ដង?

សឿនៈ	បាទ ។

កុសលៈ	ហេតុអីមិនចូលពីមុន ចូលឆ្នាំ៧៣?

សឿនៈ	វានៅស្ទើរពេក ។

កុសលៈ	គេប្រកូកប្រកាសយ៉ាងម៉េចទៅក្នុងភូមិហ្នឹង ពេលគេមកពេលហ្នឹង?

សឿនៈ	គេមិនប្រកូកប្រកាសទេ គេនិយាយថាយ៉ាងម៉េចទេវ៉ើយ គេថានាំគ្នាទៅគគ្រឹកគគ្រាក់រំដោះជាតិៗ យ៉ាងម៉េចត្រង់ណា ។

កុសលៈ	រំដោះជាតិពី ។

សឿនៈ	របបស្អីគេ ។

កុសលៈ	លន់ នល់?

សឿនៈ	ហ្នឹងហើយ ។

កុសលៈ	លន់ នល់ របបអាមេរិចហ្នឹង ។

សឿនៈ	បាទ ។

កុសលៈ	ហើយក្នុងភូមិចូលច្រើនទេ?

សឿនៈ	ច្រើន ទាំងប្រុស ទាំងស្រី ចូលគគ្រឹកគគ្រេង ខ្លះនៅតែម៉ែចាស់ ឪចាស់ ។

កុសលៈ	ចូលហ្នឹងដោយសារ បដិវត្តន៍ជំនាន់ហ្នឹង រំដោះប្រទេសជាតិយើងឲ្យមានឯករាជ្យពីរបបអាមេរិចកាំង?

សឿនៈ	អត់ដឹង មកហ្នឹងអត់ដឹងទេ បើខ្ញុំមកតាមគេដែលហ្នឹង ឃើញគេមកច្រើន គេទៅអស់ហើយ អ្នកមកវិញគេថាឯងស ឯងស្រួយអីចឹង ក៏មកហ្នឹងគេដែរ ។

កុសលៈ	ចុះធ្វើទាហាន ម៉េចមិនសំរេចចិត្តធ្វើអីផ្សេង?

សឿនៈ	អាហ្នឹងជារឿងផ្សេង ឧទាហរណ៍ក្នុយឯងអីចឹង ទូទៅគេទៅហើយ នៅអីតែយើង គេក៏ម៉េច យើងក៏ម៉េច ។

កុសលៈ	ពេលហ្នឹងអត់មានខ្លាចស្លាប់ទេ ធ្វើទាហានអីចឹង?

សឿនៈ	អត់ទេ មិនដែលដឹងថាស្លាប់វាយ៉ាងម៉េច គេនាំធ្វើចេះធ្វើហ្នឹងគេទៅ ។

កុសលៈ	គ្រួសារពេលហ្នឹងមានសមាជិកប៉ុន្មាននាក់ដែរ ពេលមុន៧៣?

សឿនៈ	ក្រុមគ្រួសារខ្ញុំមានតែ៤នាក់ទេ ។

កុសលៈ	អីចឹង៤នាក់ មានន័យថាឪពុកម្ដាយ ហើយនឹងប្អូន២នាក់ ។

សឿនៈ	ទេ ។

កុសលៈ	បងប្អូន៤នាក់?

សឿនៈ	បងប្អូន៤នាក់ទេ ។

កុសលៈ	ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

សឿនៈ	ស្រី២ ប្រុស២ ។

កុសលៈ	ប្រុសចូលធ្វើទាហានទាំង២នាក់?

សឿនៈ	អត់ទេ លោកបងខ្ញុំគាត់បានប្រពន្ធផុត ។

កុសលៈ	បានប្រពន្ធផុតគាត់អត់ចូលទេ?

សឿនៈ	បាទ ។

កុសលៈ	ចុះស្រីៗ?

សឿនៈ	ស្រីមួយបានប្ដីផុតដែរ ហើយមួយស្លាប់ ។

កុសលៈ	ស្លាប់ជំនាន់ណា?

សឿនៈ	ស្លាប់៧២ ។

កុសលៈ	ហើយឪពុកម្ដាយលោកពូធ្វើស្រែ?

សឿនៈ	ធ្វើស្រែចម្ការធម្មតា ។

កុសលៈ	អីចឹងលោកពូកាន់សាសនាអីដែរ?

សឿនៈ	ព្រះពុទ្ធដូចតែគ្នា ។

កុសលៈ	ព្រះពុទ្ធដូចខ្ញុំដែរ ។

សឿនៈ	ណាទៅកាន់សាសនា យេស៊ូ អីណា ។

កុសលៈ	ក្រែងលោមានអ៊ីស្លាមអីចឹង ។

សឿនៈ	អត់ទេ ។

កុសលៈ ទំនៀមទំលាប់ខ្មែរយើង ។

សឿនៈ បាទ ។

កុសលៈ អ៊ីចឹងមុន៧៥ហ្នឹងគឺថាជីវិតលោកពូ-អ្នកមីង យ៉ាងណាដែរ? លោកពូយ៉ាងណាដែរ គ្រួសារក្រ មធ្យម បង្គួរ ឬមាន?

សឿនៈ គ្រួសារ ផ្ទះសំបែង?

កុសលៈ បាទ ចាត់ទុកថាជាអ្នកក្រ មធ្យម?

សឿនៈ ដូចតែគេឯង យើងធម្មតា មានស្រែ មានចម្ការ មិនក្រណាស់ពេក ។

កុសលៈ មធ្យម ។

សឿនៈ មិនមានលើសគេទេ ។

កុសលៈ លោកពូការហើយ ឬនៅពេលហ្នឹង រៀបការ?

សឿនៈ នៅទេ ។

កុសលៈ ក៏មិនទាន់មានកូនមានចៅដែរ នៅក្មេង?

សឿនៈ អត់ទាន់មានទេ នៅក្មេង ។

កុសលៈ អ៊ីចឹងពេល៧៣ហ្នឹងនៅស្ទឹងត្រែង?

សឿនៈ អត់ទេ ចូលកងទ័ពគេឲ្យនៅ ។

កុសលៈ ៧៣ហ្នឹងចូលកងទ័ពហើយ?

សឿនៈ បាទ ។ គេឲ្យមកនៅ ។

កុសលៈ ចាំខែទេ ចូលកងទ័ព?

សឿនៈ ខែ៦ ។

កុសលៈ ខែ៦ ឆ្នាំ១៩៧៣?

សឿនៈ បាទ ។

កុសលៈ អាយុប៉ុន្មានចាំទេពេលហ្នឹង?

សឿនៈ មិនដឹងប៉ុន្មាន ប្រហែល១៥-១៦ហ្នឹង ។

កុសលៈ នៅក្មេងណាស់?

សឿនៈ ក្មេង ។

កុសលៈ រៀនថ្នាក់ទីប៉ុន្មានហើយពេលហ្នឹង?

សឿនៈ មិនបានរៀនទេ ពីដើមម៉ិញយើងថារៀនថ្នាក់១២ចុះ ។

កុសលៈ ថ្នាក់ទី២-៣ឥឡូវ?

សឿនៈ ហ្នឹងហើយ ។

កុសលៈ ១២ហ្នឹងថ្នាក់ទី១-២?

សឿនៈ បាទ ។ ថ្នាក់ទី១២ហ្នឹងថ្នាក់កុមារដ្ឋានហើយពេលហ្នឹង ហើយរៀនដល់ថ្នាក់ទី១០មើល ទៅរៀនបានមួយឆ្នាំជាងដែរ ។

កុសលៈ រៀនដល់ថ្នាក់ទី១០?

សឿនៈ បាទ ។

កុសលៈ ហេតុអីរៀនអត់បានច្រើនពូ? ដោយសារតែសង្គ្រាម គ្រួសារមធ្យមដែរ ហេតុអីបានអត់រៀន?

សឿនៈ សង្គ្រាមរាល់ថ្ងៃ ហើយមានគ្រួឯណាបង្រៀនបើគ្រាប់ផ្លោងធ្លាក់រាល់ថ្ងៃ កប៉ាល់ហោះឆាបរាល់ថ្ងៃទៅធ្វើម៉េចបានរៀន រដ្ឋប្រហារតាំងពីឆ្នាំ៧០ហើយ ។

កុសលៈ ទម្លាក់គ្រាប់បែក?

សឿនៈ ទម្លាក់គ្រាប់បែកលិចកើតទៅ ។

កុសលៈ ពូនៅចាំព្រឹត្តិការណ៍អាមេរិចកាំងទម្លាក់គ្រាប់បែកទេ?

សឿនៈ ចាំខ្លះដែរហ្នឹង ។

កុសលៈ ហើយចុះភូមិពូមានខូចខាតច្រើនទេ?

សឿនៈ និយាយរួមអ្នកនៅតាមមាត់ទន្លេមេគង្គ វាខូចសំណាំដែរ ។

កុសលៈ អីចឹងពូនៅតាមដងទន្លេមេគង្គ?

សឿនៈ បាទ នៅតាមដងទន្លេមេគង្គឡើងទៅលាវ ។

កុសលៈ អីចឹងប៉ះពាល់ច្រើនពេលអាមេរិចកាំងទម្លាក់គ្រាប់បែក?

សឿនៈ បាទ ។

កុសលៈ អីចឹងមូលហេតុចំបងដែលលោកពូចូលបដិវត្តន៍ ដោយសារការទម្លាក់គ្រាប់បែក ឬដោយសារដូចលោកពូថាមុន ឃើញគេចូលព្រាតរំដោះទឹកដី?

សឿនៈ នឹកឃើញថានៅវាលំបាកដែរ ម្យ៉ាងទស្សនៈខ្លួនឯងអស់សង្ឃឹម បើយើងមិនជួយជាតិមិនដឹងជាជួយអ្នកណា ម៉្លោះមកក្នុងទស្សនៈរបស់ខ្លួនឯង ដើម្បីផ្សះផ្សារជាតិដែលហ្នឹង ។

កុសលៈ ពូចាំថាក្រោយមកទៀតគេបញ្ជូនទៅណា? បន្ទាប់ពូចូលទាហាន គេបញ្ជូនទៅណា ទៀត?

សឿនៈ បញ្ជូនមកខេត្តព្រះវិហារ ។

កុសលៈ មកព្រះវិហារ?

សឿនៈ បាទ ។

កុសលៈ ឆ្នាំ៧៣ហ្នឹង?

សឿនៈ បាទ ៗ មកនៅព្រះវិហារ ។

កុសលៈ ហើយគេឲ្យធ្វើអីទៀត ព្រះវិហារ?

សឿនៈ ធ្វើកងទ័ពធម្មតា ។

កុសលៈ ហេតុអីបានគេបញ្ជូនមកព្រះវិហារ?

សឿនៈ ថាកងចល័តគេមិនដឹងម៉េច យើងចេះតែដើរ ត្រូវការត្រង់ណា ដូចថាកងចេះ កងនេះ ព្រះវិហារទៅនៅស៊ឹងត្រែង ពីស៊ឹងត្រែងមកនៅព្រះវិហារ គេហៅថាចល័តកងទ័ពម៉េចណាគេនោះ ។

កុសលៈ ហើយការរស់នៅ ហូបចុកពេលនោះអត់អីលំបាក?

សឿនៈ ទេ ដូចមិនមានអីផង ហូបធម្មតា ដូចតែយើង ។

កុសលៈ កាលហ្នឹងចូលក្នុងកងពល ក្នុងវរៈចាំមេបញ្ជាការទេ?

សឿនៈ មិនចាំទេ ភ្លេចអស់ហើយ ។

កុសលៈ ដល់ក្រោយមកពេលហើយ ប្រទេសរំដោះពេលថ្ងៃ១៧ មេសា ៧៥ ពូនៅកន្លែង ដដែលឬគេបញ្ជូនទៅផ្សេង?

សឿនៈ អត់ទេ នេះខ្ញុំនៅឧត្ដរមានជ័យ ។

កុសលៈ គេបញ្ជូនមកឧត្ដរមានជ័យទៀត ។

សឿនៈ បាទ ។

កុសលៈ ពូចាំថ្ងៃហ្នឹងទេ ព្រឹត្តិការណ៍រំដោះ សភាពការណ៍យ៉ាងម៉េចទៅពេលហ្នឹង ប្រជាជនអបអរសាទរ ថ្ងៃហ្នឹងគេមានប្រារព្ធធ្វើពិធីជប់លាង ធ្វើអីអត់? ថ្ងៃដែលប្រទេស រំដោះថ្ងៃ៧៥ហ្នឹង?

សឿនៈ ថ្ងៃ១៧មេសាហ្នឹង?

កុសលៈ បាទ ដែលបដិវត្តន៍ទទួលជោគជ័យលើពួក លន់ នល់?

សឿនៈ បើខាងកន្លែងកងទ័ពគេជប់លាងដែល គេជប់លាងអបអរ តែខ្ញុំនៅតាមព្រំដែនមិនដឹង ផងមិនដឹងគេជប់អី ថ្ងៃណាក៏ថ្ងៃហូប នៅព្រំដែនធម្មតា មិនដឹងខាងក្នុង ខាងក្រៅគេធ្វើម៉េចមិនដឹងទេ មិនដែលចូលសាលានយោបាយ នៅតែការពារព្រំដែន ។

កុសលៈ ក្រោយមកទៀត ក្រោយ៧៥?

សឿនៈ ក្រោយពី៧៥មក គឺ៧៧ ។

កុសលៈ ក្រោយមកគេឲ្យទៅណាទៀត?

សឿនៈ នៅតែហ្នឹង ។

កុសលៈ នៅការពារព្រំដែន?

សឿនៈ បាទ ។

កុសលៈ ព្រំដែនព្រះវិហារ?

សឿនៈ បាទ ។

កុសលៈ ហើយមានប៉ះដាមួយថៃទេ ពេលហ្នឹង?

សឿនៈ កាលហ្នឹងអត់មានប៉ះទេ អព្យាក្រឹតរាងខ្លួន នៅតំបន់វានៅហៅថាព្រំដែនវាច្បាស់ អត់មានប៉ះពាល់គ្នាទេ ។

កុសលៈ ពូមានបានឡើងទៅប្រាសាទព្រះវិហារទេពេលហ្នឹង?

សឿនៈ មិនដែលបានឡើងផង ទើបតែឡើងសម័យក្រោយហើយ កាលសម័យយើង ។

កុសលៈ សង្គ្រាមស៊ីវិល?

សឿនៈ សង្គ្រាមស៊ីវិលហើយ ។

កុសលៈ ចុះក្រោយមកទៀតលោកពូ?

សឿនៈ ក្រោយពី ។

កុសលៈ ពេលទ័ពវៀតណាមចូលមក ពូចាំថ្ងៃទេ ៧៨-៧៩ហ្នឹង ប្រទេសជាតិមានការប្រែប្រួលមិនអីចឹង?

សឿនៈ កាលដែលវៀតណាមចូលមកកម្ពុជា ខ្ញុំនៅធ្វើកងទ័ពដដែល ។

កុសលៈ កងទ័ពរហូត?

សឿនៈ បាទ កងទ័ព មិនដឹងជាសភាពការណ៍គេយ៉ាងម៉េចអីយ៉ាងម៉េច មិនដឹងហ្នឹងគេ គេប្រាប់ទៅណាក៏ទៅហ្នឹងគេ គេប្រាប់ឲ្យទៅច្បាំងក៏ទៅច្បាំង មិនដឹងថាយ៉ាងណា ទិសដៅយ៉ាងណាអត់ដឹងទេ ។

កុសលៈ កាលហ្នឹងនៅក្នុងកងពលលេខប៉ុន្មាន?

សឿនៈ កងពលលេខប៉ុន្មានទេ កងពលលេខ៨ ។

កុសលៈ កងពលលេខ៨ការពារតំបន់ព្រះវិហារ?

សឿនៈ បាទ ។

កុសលៈ អ្នកណាជាអ្នកកាន់ពេលហ្នឹង មេកងពលលេខ៨ នៅចាំទេ?

សឿនៈ ភ្លេចហើយ ឈ្មោះហង្ស ។

កុសលៈ នៅរស់ ឬស្លាប់ហើយ?

សឿនៈ	មិនដឹងនៅរស់ ឬស្លាប់ទេ ឥឡូវមិនដែលដឹង ។

កុសលៈ	ត្រឡប់នៅក្នុងរបបពាឆ្នាំហ្នឹងតើពូដែលទៅលេងគ្រួសារដែរ?

សឿនៈ	អត់ដាច់ទល់ឥឡូវ ។

កុសលៈ	អត់ដែលលឺ អត់ដែលដឹង?

សឿនៈ	អត់ដែលលឺ អត់ដែលដឹងទេ ទល់ឥឡូវ ។

កុសលៈ	ដូចនៅប្អូនស្រីម្នាក់ ប្រុសម្នាក់?

សឿនៈ	ប្រុសហ្នឹងបងគេបង្អស់ ។

កុសលៈ	នៅរស់ ។

សឿនៈ	នៅរស់កាលខ្ញុំចេញមកនៅរស់ ។

កុសលៈ	តែឥឡូវមានដឹងទេ?

សឿនៈ	អត់ដែលដឹង ស្រីក៏នៅរស់ដែរ ។

កុសលៈ	អត់ដែលដឹងដំណឹង?

សឿនៈ	អត់ដែលដឹងដំណឹង អត់ដែលទៅផង ។

កុសលៈ	លោកពូមានដែលត្រឡប់ទៅវិញ ដើម្បីតាមរកទេ?

សឿនៈ	អត់ទេ ។

កុសលៈ	ម៉េចអី ហេតុអី?

សឿនៈ	អត់មានអី ដូចមិនមានអារម្មណ៍អីនឹកឃើញថាវា សន្មត់ខ្លួនឯងថាមិននឹកឃើញថាបង ស្រីបងប្រុសនៅរស់ផង តាមមើលទៅ បើខ្ញុំពៅគេប៉ុណ្ណឹងហើយចុះគាត់ហើយនឹងខ្ញុំមិន មែន១ឆ្នាំមួយណា ៥-៧ឆ្នាំមួយ ដល់អីចឹងខ្ញុំថាគ្មាន ។

កុសលៈ	ប្រហែលជាគាត់ស្លាប់អស់ហើយ ។

សឿនៈ	អីចឹងខ្ញុំខ្ជិលទៅ ។

កុសលៈ	កូនក្មួយក៏មិននេះដែរ?

សឿនៈ	អត់មានអ្នកណាអើពើផង គិតទៅខ្ជិល ម្យ៉ាងធ្វើកងទ័ពកាលនោះចេញពីភូមិទាំងអស់គ្នា បែកបាក់គ្នាខ្លះស្លាប់ ខ្លះក៏គេទៅផ្ទះវិញ នៅតែខ្ញុំ ដាច់ចូលតែខ្ញុំ មិនដឹងរកអ្នកណាទៅ ហីទៅ ដូចហីយើងអត់មានអារម្មណ៍ចង់ទៅបន្តិចទេ ។

កុសលៈ	មិនដែលនឹកនាថាកាលពីក្មេងថានៅនោះ?

សឿនៈ	អត់ទេ ភ្លេចអស់ហើយ ។

កុសលៈ	ជួបអ្នកមីងពេលណា?

សឿនៈ ឆ្នាំ៨០ ។

កុសលៈ ទើបតែជួប៨០ ?

សឿនៈ បាទ ។

កុសលៈ អីចឹងពូមិនដែលរៀបការពីមុនមកទេ? ជួបគាត់ទី១ ?

សឿនៈ មិនដែលទេ ។

កុសលៈ ពេលពូរៀបការ៨០ អាយុប៉ុន្មានហើយ?

សឿនៈ អាយុទើប ។

កុសលៈ ២៧ ៨០ អាយុ២៧ឆ្នាំ?

សឿនៈ មិនមែនទេ ។

កុសលៈ ពូរៀបការអាយុប៉ុន្មាន?

សឿនៈ សែជាងហើយ ។

កុសលៈ អ្ហ៎ា ប៉ែតជាង ត្រូវហើយសែជាង ។ រៀបការរាងយឺតដែរ ។

សឿនៈ បាទ ។

កុសលៈ អីចឹងពេលជួបអ្នកមីង ជួបគ្នានៅក្នុងយោធា ឬយ៉ាងម៉េច?

សឿនៈ បាទ ជួបយោធាគេធ្វើយោធាដូចតែគ្នា ។

កុសលៈ កាលជំនាន់ពាឆ្នាំគាត់ដែលអង្គការចាត់តាំងឲ្យជួប មានគ្រួសារមានអី?

សឿនៈ មិនដែលស្នើរគេផង មិនដែលមានអារម្មណ៍ថាចង់បានផង ខ្ជិល មិនដែលសុំគេ ហើយ
ម្យ៉ាងនៅតែព្រំដែន ដុបព្រៃមិនដែលឃើញស្រីឃើញញីហ្នឹងគេផង ។

កុសលៈ ម៉េចបានជួបអ្នកមីង ដោយចៃដន្យ ឬម៉េច?

សឿនៈ ដោយចៃដន្យទេ ជួប៨០ហ្នឹងកាលហ្នឹងយើងមិនមូលគ្នាដល់អីចឹងជួបគ្នា ក៏បាន
ស្រលាញ់គ្នាយលគ្នាទៅ ។

កុសលៈ មានកូនប៉ុន្មានហើយ?

សឿនៈ កូន៤-៥នាក់ ។

កុសលៈ ហើយអ្នកមីងកាលហ្នឹងគាត់នៅក្នុងកងពលជាមួយគ្នា ឬក៏?

សឿនៈ អត់ទេ គេនៅពួកខាងណាទេ មិនបានស៊ើបសួរផង មិនដឹងគេនៅខាងណា ជួបគ្នា
ស្រលាញ់ យកគ្នាទៅ ។

កុសលៈ ហើយអ្នកមីងអ្នកស្រុកណាដែរ?

សឿនៈ អ្នកកំពង់ចាម ។

កុសលៈ	គិតទៅមកពីខេត្តផ្សេងៗគ្នាតំបន់នេះ ។

សឿនៈ	បាទ ។

កុសលៈ	មានមកពីតាកែវ កំពត ពូស៊ីនវែត្រង កំពង់ចាម និយាយរួមអន្លង់វែងមានមកពីគ្រប់ទាំងអស់ ។

សឿនៈ	គ្រប់ទិសទី អត់មានអ្នកស្រុកអន្លង់វែងដូចគ្នាទេ ។

កុសលៈ	សុទ្ធតែមកផ្សេង ។

សឿនៈ	អ្នកអន្លង់វែងនៅថៃសព្វថ្ងៃ ។

កុសលៈ	ប៉ុន្តែមកហើយមិនទៅស្រុកវិញទៀត ។

សឿនៈ	មិនទៅទេ ។

កុសលៈ	ហេតុអី ដូចលោកពូមិនទៅស្រុក អ្នកមីងក៏នៅនេះ?

សឿនៈ	ដូចមានអារម្មណ៍ដែលហ្នឹង តាមមើលទៅ ។

ប្រពន្ធៈ	មកយូរទៅមិននឹកបងប្អូនទេ ។

សឿនៈ	លែងនឹកនាអស់ ម្យ៉ាងវាគ្មានថវិការផង វាពិបាក កាលពីដើមម៉ិញវាពិបាកដើរចុះដើរឡើង ឥឡូវមានថវិការគេទៅផ្លូវស្រួលហើយ ក៏ដូចមានអារម្មណ៍ហីទៅ ។

ប្រពន្ធៈ	ឃើញបែកគ្នាយូរហើយហីៗ សព្វថ្ងៃបើសិនគេថាបងគាត់ស្លាប់ហើយ អត់មានអារម្មណ៍យំ ។

កុសលៈ	វាបែកយូរពេក ។

សឿនៈ	បែកយូរពេក ។

ប្រពន្ធៈ	បែកតាំងពីជំនាន់ក្មេង ឥឡូវឡើងអាយុហាហើយ បានថាគ្មានអារម្មណ៍យំ ដល់គេថាងាប់ ។

កុសលៈ	គិតទៅមានបងប្អូនបែកបាក់គ្នាអស់រលីង រាប់សិបឆ្នាំ ។

សឿនៈ	រាប់សិបឆ្នាំ ។

កុសលៈ	ពេលខ្លះមាននឹកថាចង់ជួបពួកគាត់វិញទេ សួរម៉េចម៉ាអី បងប្អូន?

សឿនៈ	នឹកឃើញខ្លះ ថ្ងៃណានឹកឃើញអារម្មណ៍ចង់ជួបបងជួបប្អូនដែរ តែគិតតែមួយភ្លែតបាន ត្រឹមតែគិត ប៉ុន្តែមិនទៅ មិនមានអារម្មណ៍ទៅ និយាយថាគ្មានអារម្មណ៍ទៅតែ មួយគិតបើទៅមិនដឹងទៅជួបអ្នកណា បើប៉ុន្មានសិបឆ្នាំទៅហើយ មិនដែលមានទំនាក់ទំនងបន្តិចផង មិនដឹងទៅជួបយ៉ាងម៉េចកើត គិតទៅផ្លូវហ្នឹងផ្សេង ។

កុសលៈ ចុះក្រោយមកទៀត ទសវត្ស៨០ កាលហ្នឹងយើងមានសង្គ្រាមស៊ីវិល ពួកវៀតណាម ដកចេញទៅ ឆ្នាំ៨៨-៨៩ ពេលហ្នឹងសភាពការណ៍តំបន់នេះ ខ្ញុំឃើញច្របូកច្របល់ ជាពិសេសតំបន់សៀមរាប-ឧត្តរមានជ័យ កាលហ្នឹងពួកវៀតណាមចូលលុកលុយមក ដល់នេះ លោកពូមានវៃជាមួយពួកហ្នឹងច្រើនទេ?

សឿនៈ ទេ កាលនោះតំបន់នេះនិយាយរួមមិនមានអ្នកណានៅទំនេរបានទេ។

កុសលៈ មីនក៏ច្រើន?

សឿនៈ អ៊ីៗគិតទៅសស្រាក់សស្រាំការពារដូចតែគ្នា គេក៏គេ យើងក៏យើង នៅកងរាងៗខ្លួន អត់ ដែលមានទំនេរទេគិតទៅ។

កុសលៈ វៃគ្នារហូត។

សឿនៈ មិនថាបុគ្គលណា និយាយរួមឲ្យតែជួរព្រំដែនស្រុកអន្លង់វែងនេះ។

កុសលៈ វៃរហូត?

សឿនៈ សុទ្ធតែកងទ័ពទាំងអស់ វាមានច្រើនផ្នែក ខ្លះគេនៅព្រំដែន មានព្រំដែនដូចគ្នា ហើយ ខ្លះគេចូលទៅក្នុងៗអីចឹងទៅ តាមលទ្ធភាព។

កុសលៈ ពូនៅក្រោមបងផាន់ណា អត់ទេ? នៅក្រុមជាមួយគ្នា ឬយ៉ាងម៉េច?

សឿនៈ មុនដំបូងនៅជាមួយគ្នា នៅ៩៨០ដូចគ្នា។

កុសលៈ កងពល៩៨០?

សឿនៈ បាទ។

កុសលៈ ហើយគាត់ទៅក្រោមផ្តាច់ខ្លួនទៅ។

សឿនៈ បាទ។ ផ្តាច់ខ្លួនទៅគេឲ្យខ្ញុំទៅនៅភ្នំដាច់។

កុសលៈ គាត់កាន់កងពល ឬកងវរៈ?

សឿនៈ មុនដំបូងកាន់កងវរៈទេ។

កុសលៈ គាត់ធំដែរ?

សឿនៈ បាទ។

កុសលៈ មុននឹងរៀបផ្តាច់ខ្លួនសភាពការណ៍យ៉ាងម៉េចដែរពេលហ្នឹង? ព្រោះមានអ្នកខ្លះទៅ អ្នកខ្លះ មិនទៅ? លោកពូចាំបានទេ?

សឿនៈ ពេលផ្តាច់ខ្លួនវាមិនដឹងរឿងរាងៗខ្លួន។

កុសលៈ សុទ្ធតែជាការសំងាត់?

សឿនៈ ស្រាប់តែ អានេះទៅនោះ ដល់គ្នាទៅ គេថាអាពួកនោះទៅហើយសុទ្ធតែពួកក្បត់ ឯងនេះទៅណាគេចេះ ហ៎ ទៅនោះ ទៅហ្នឹងគេទៅ ។ សាកាដូមួយស្អាយរិចអស់ហើយ ជើងត្បូង ត្បូងជើង គ្រាន់តែធូរខ្ញុំបានមេមួយគាត់ពិការជើងទៅនៅជាមួយមេហ្នឹង មិនសូវបានហ៊ឹកហ៊ឺនទៅមុខនឹងគេប៉ុន្មានទេ នៅហ្នឹងក្រោយជួយមីងៗរែក គាត់ផ្តាច់រត់ ទៅកើតអីចឹងទៅ ។

កុសលៈ ពីណាមេរបស់ពូដែលពិការជើង?

សឿនៈ នេះ តាប៉ែន នឹម ។

កុសលៈ ខ្ញុំជួបគាត់ គាត់ជួបពូឯងមុនដែរ ។ គាត់ពិការជើងដែរ នៅជាមួយពូនឹម ហ្នឹង? គាត់កងវរៈអីចឹង?

សឿនៈ បាទ ។

កុសលៈ គាត់ឡើងទៅជាមួយតាទៅ?

សឿនៈ ទៅលើជាមួយគេទៅ ។

កុសលៈ អីចឹងបានថាបើគាត់ផ្តាច់ខ្លួនមកមុន គាត់ក៏ធ្វើធំដែរ បានចៅហ្វាយស្រុកហ្នឹងគេដែរ ។

សឿនៈ មិនដឹងដែរ មិនស្រួល ផាន់ណា អត់បានទាន់គាត់ទេ ។

កុសលៈ អត់ទាន់គាត់ទេ គាត់និយាយមកគាត់ដឹងច្រើន នឹម ហើយមាឌគាត់ធំ ។

សឿនៈ កាលហ្នឹងកាលនៅ ។

ប្រពន្ធៈ ប្រពន្ធគាត់ក៏កំបុតជើងដែរ ។

កុសលៈ ដៃទៀត ។

សឿនៈ កាលគាត់នៅជាមួយ ផាន់ណា ហ្នឹងរងរបស់គាត់ ។

កុសលៈ បងផាន់ណា រងរបស់គាត់ ។

សឿនៈ បាទ ។

កុសលៈ គិតទៅក្រឡាប់ចាក់អស់ ប៉ុន្តែខ្ញុំអត់យល់ថាហេតុអីបានបែកគ្នាពីរនាក់ហ្នឹង បងផាន់ណាគាត់រង ហើយហេតុអី ពូនឹម ហ្នឹងគាត់ ។

សឿនៈ ផាន់ណា គេនៅកាន់ទ័ពជាប់ ហើយបងនេះគាត់នៅកន្លែងពិការ ។

កុសលៈ គាត់ពិការហើយៗ?

សឿនៈ នៅកន្លែងពិការគេបញ្ចូលមកមួយកងអីចឹងទៅ ដូចថាខ្ញុំធ្លាប់នៅជាមួយគ្នាពីដើមម៉ិញក៏ប្រមូលគ្នាទៅនៅជាមួយគាត់ ។ ហើយ ផាន់ណា គេកាន់កងទ័ពជាប់ក៏គេដោយឡែកគេទៅ ។

កុសលៈ បងផាន់ណា ហ្នឹងអនុទេ?

សឿនៈ ដល់គាត់មកនៅពិការគេឡើងនោះទៅ គាត់ក៏សាមញ្ញយើងធម្មតា ប៉ុន្តែតួនាទីនៅធម្មតា តែអត់មានសិទ្ធកាន់កងទ័ពទៀតទេ យើងពិការហើយ មានតែប៉ុណ្ណឹង ។ ដល់នេះ គេឡើងទៀតទៅ ។

កុសលៈ គិតទៅប្រវត្តិសាស្រ្តមិនទៀងទេ ។

សឿនៈ មិនទៀងទេ ។

កុសលៈ អ្នកខ្លះបានឡើងទៅ ដូចថាខុសគ្នា សំណាងខុសៗគ្នា ។ ពេលហ្នឹងលោកពូមានឃើញមានចាំតាៗគាត់ចុះដាប់? តា ម៉ុក?

សឿនៈ តា ម៉ុក ខ្ញុំចាំមុខច្បាស់ ។

កុសលៈ ដែលឃើញ ប៉ុល ពត ទេ?

សឿនៈ បើ ប៉ុល ពត អត់ទេ ។

កុសលៈ ហេតុអីខ្ញុំឆ្ងល់សួរគ្រប់គ្នាមិនដែលឃើញគាត់?

សឿនៈ មិនដែលឃើញទេ ។

ប្រពន្ធៈ ដែលលឺ ។

សឿនៈ លឺតែឈ្មោះ មុខមិនដឹងយ៉ាងណា ។

កុសលៈ គាត់នៅហ្នឹងទេ?

សឿនៈ នៅតែនេះ ប៉ុន្តែយើងមិនស្គាល់ មិនដឹង ប៉ុល ពត មួយណា បើ តា ម៉ុក ដែលស្គាល់គាត់ច្បាស់ដោយសារគាត់ដាច់ជើង ។

កុសលៈ ហើយគាត់ដើរចុះគ្រប់ផ្ទះ ។

សឿនៈ ដើរដេរគ្រប់ផ្ទះ បានប៉ុណ្ណឹង ស្គាល់ប៉ុណ្ណឹង មេៗខាងលើមិនដែលស្គាល់គេទេ មិនដឹងមួយណា ពត, មួយណា ខៀវ សំផន មិនដឹងមួយណា សុន សេន មិនស្គាល់គេទេ

ប្រពន្ធៈ លឺតែគេហៅៗតាមគេ ។

សឿនៈ ហៅហ្នឹងគេ ។

កុសលៈ គាត់មិនដែលចេញមកដើរឲ្យប្រជាជមើលទេ ។

សឿនៈ បើគេអ្នកស្គាល់គេថាគាត់ចេញ ណាស់តែយើងមិនដែលស្គាល់ មេៗគេថាតានេះមកពីនេះ តានោះមកពីនោះ អាគេទៅបាត់ហើយបានគេប្រាប់ក្រោយ ប៉ុន្តែថាទៅដូចក្នុយឯងដឹងស្រាប់ហើយ ទាំងយើងទាំងគេរក្សាសុខរាងតែខ្លួន អ្នកណាមកពីណាក៏មកទៅ កុំតែធ្វើទុក្ខបុកម្នេញយើង ឲ្យតែបានសុខក្រុមគ្រួសារយើងបានហើយ ។

កុសលៈ ពេលសមាហរណកម្មហើយ ពេលហ្នឹងឆ្នាំប៉ុន្មាន៩៨?

សឿនៈ ៩៨ ។

កុសលៈ ពូចូលជាមួយរដ្ឋាភិបាលហើយឆ្នាំណា?

សឿនៈ ៩៨ហ្នឹង ។

កុសលៈ ពេលចូលមកហ្នឹងគេជួយអីខ្លះ?

សឿនៈ កាលនោះគេបានឲ្យខ្លះយាយ?

ប្រពន្ធៈ បានអង្ករ បានម្ហូប ។

សឿនៈ បានតង់ ។

កុសលៈ ប្រគល់អាវុធឲ្យគេអស់ទៅ?

សឿនៈ បាទ ។

ប្រពន្ធៈ មានអាវុធឯណា ។

សឿនៈ អត់មានអាវុធទេពូកខ្ញុំ អត់មាន នៅពិការអត់មានអាវុធទេ ។

កុសលៈ លោកពូរបួសអីគេ ពិការ?

សឿនៈ អត់របួសទេ ប៉ុន្តែនៅជាមួយតាហ្នឹង គេដកតាំងពីគាត់មកនៅកន្លែងពិការ ខ្ញុំមិនដែលមានអាវុធទេ អត់ ។

ប្រពន្ធៈ តាំងពីមិនទាន់ចប់សង្គ្រាម គាត់ទៅនៅកន្លែងពិការនេះក៏ទៅតាម ។

កុសលៈ តាមមេរហូត ។

សឿនៈ បាទ ។

ប្រពន្ធៈ តាមសែងប្រពន្ធគាត់ ប្រពន្ធគាត់ដាច់ជើងដើរមិនរួច ។

កុសលៈ ហ្នឹងហើយខ្ញុំជួបគាត់ដែរ ឃើញប្រគោងសារ៉ូម ។

សឿនៈ មិនសូវជាដែលទេយាយហ្នឹង ។

កុសលៈ ពីរនាក់គាត់ដូចស្រលាញ់គ្នាសំបើមណាស់ ជួបអង្គការរៀបឲ្យ ។ ប្រពន្ធគាត់ធ្វើទាហានដែរ?

សឿនៈ យាយហ្នឹងកងដឹកជញ្ជូន ។

កុសលៈ គាត់ប្រាប់ខ្ញុំដែរកងដឹកជញ្ជូន ។ ខ្ទាំងដែលកំបុតដៃបួន សល់ម្រាមមួយជើងទៀត ។

សឿនៈ ជើងនោះបើតាមពេទ្យគេ បើគាត់ឲ្យគេកាត់ដាក់ជើងសិប្បនិមិត្តដើរបានស្រួលហើយ តែគាត់អៀននឹងគេណាស់ មិនហ៊ានឲ្យគេកាត់ ។ បើឲ្យគេកាត់ធម្មតាកាលនោះអាយុវានៅល្មមៗវាជាបាត់ទៅហើយ ដាក់ជើងដើរកើល ។

ប្រពន្ធ: តាំងពីគាត់មិនបានកូន ។

សឿន: មិនទាន់មានកូន ។

ប្រពន្ធ: ឥឡូវបានចៅទៀត ។

សឿន: ចង់បានចៅតួនទៀតហើយ ដល់អីចឹងគាត់នៅតែរុំបង់ ក្រណាត់សហ្នឹង ដើរភឹបៗដូចជើង ដីរ ខ្ញុំតែងថាយាយឯងកើតជើងដីរមួយជីវិតហើយ គេនាំទៅកាត់មិនព្រមទៅ កាត់ទេ ទុកធ្វើអី អាជើងដាច់ ដៃដាច់ ។

កុសល: ឃើញគាត់បេះតែលាក់ គាត់បាំងកុំឲ្យឃើញ ។

សឿន: លាក់កំបាំងមិនឲ្យឃើញ អ្នកណាទៅនេះបើឃើងដំណើរខុស មិនឲ្យពេទ្យគេកាត់កុំអីដើរ រួចសព្វថ្ងៃ ដើរភឹលបាត់ ។

ប្រពន្ធ: យាយដាច់ជើងមុនតា ។

កុសល: គាត់ដាច់ជើងជិនាន់ណាមីង?

សឿន: យាយហ្នឹង ប៉ែតប៉ុន្មានទេ តានេះដាច់ជើង៨៤ ឆ្នាំ៨៤ យាយហ្នឹងអាច៨៣ មួយឆ្នាំ ម្នាក់ ។

ប្រពន្ធ: តែគាត់តាមប្រពន្ធគាត់ជាប់រហូតដល់សព្វថ្ងៃ ។

កុសល: សរសើរគាត់ ។

ប្រពន្ធ: ខ្វះគេលែងចោល ។

កុសល: នៅជាមួយគ្នារហូត ។

សឿន: គាត់មិនដែលបេះឈ្មោះគ្នាទេ គាត់គិតតែរឿងចម្ការស្រែ សណ្តែក រឿងពោត គោយន្ត គាត់មួយយាយតាទៅហើយ តែយាយទៅៗហើយ តែព្រលឹមឡើងទៅស្រែបាត់ បេះ ឪឡឹកគាត់ ខែឪឡឹកៗ ខែសណ្តែកៗ ។

កុសល: ស្ងោរពោតឲ្យខ្ញុំឡើងមួយចានធំ ពោត ។

សឿន: ពោតគាត់ដាំ បើខែឪឡឹក ប៉ុន្តែឥឡូវដាំវាមិនគង់ក្លួយអើយ ណាស់តែបើដេកចាំក៏ យ៉ាប់ ណាស់តែគេលួចបេះរបស់គាត់ ដឹងតែគាត់ពិការអីចឹង មានអ្នកច្រណែនហ្នឹង អ្នកពិការ ទៀត វាយ៉ាប់អីចឹង ក្មេងៗវាដើរទៅវាកាច់ ត្រឹមហូប៤-៥មានអី ខ្វះកាច់ ដាក់ការុង យកមកស្ងោរលក់ដែរ របស់គាត់មិនសមសោះ ។

កុសល: លោកពូឆ្លងកាត់មកច្រើនហើយ ធ្វើម៉េចឲ្យប្រទេសយើងមានការផ្សះផ្សារ? ខ្ញុំចង់ និយាយថាភាគច្រើនមាននៅក្នុង មានក្រៅ ហើយអ្នកក្នុងច្រើនមិនយល់ លឺតែតំបន់ អន្លង់វែងគឺថាតំបន់សុទ្ធតែព្រៃ តំបន់នោះសុទ្ធតែពួកខ្មែរក្រហម ហើយអ្នកខាងក្នុងអ្នក

ខ្លះមិនដែលមកដល់អន្លង់វែងទេ គាត់អត់ដឹងថាអន្លង់វែងអត់មានអ្នកសុំទានទេ ទៅកន្លែងផ្សេងៗសុទ្ធតែអ្នកសុំទានមួយកំនរ ។ ខ្ញុំមកឃើញផ្ទាល់ខុសពីអ៊ីដែលខ្ញុំបានដឹងពី មុនមកភាគច្រើននៅមានការភ័ន្តច្រលំច្រើន មិនអីចឹង ។ ហើយអ្នកខាងក្រៅក៏មិនដឹង ពីអ្នកខាងក្នុងដែរ ទី១ខ្លាចមិនហ៊ានទៅខាងនោះ អីចឹងខ្ញុំមានអារម្មណ៍ថាសង្គមយើង នៅមានអ្នកក្នុងនិងអ្នកក្រៅ យើងធ្វើម៉េចឲ្យប្រទេសយើងមានការផ្សះផ្សារ?

សឿនៈ ទេ អាហ្នឹង ។

កុសលៈ តាមពូមានន័យថាម៉េចទៅការផ្សះផ្សារ? និយមន័យនៃការផ្សះផ្សារធ្វើម៉េចទៅ?

សឿនៈ យើងរួមគ្នាទៅណា ហៅថារួមធ្វើអ៊ីមួយកុំឲ្យប៉ះពាល់ទៅខាងក្នុង រាជរដ្ឋាភិបាលហ្នឹងវាផ្សះផ្សារជាតិបាត់ហើយ ធ្វើអ៊ីមួយកុំឲ្យវាល្អក់កករ ម្យ៉ាងគឺយើងនៅខាងណាក៏នៅខាងហ្នឹងឲ្យវាច្បាស់លាស់ តែផលប្រយោជន៍ក៏យើងគិតមើលដែរ សំខាន់អ្នកដែល អ៊ីមួយអ្នកដែលធ្វើ អ្នកមិនធ្វើ បានតែថា អាហ្នឹងក៏យើងចំណាស់នេះហើយ ចេះវិភាគពិចារណាដែរ ឯងធ្វើអានេះឲ្យអញបន្តិច អញឲ្យអានេះអានោះ បានតែថាទេការពិតអត់បាន ខ្ញុំក៏អត់ចាញ់បោកអ្នកណា ចាញ់បញ្ឆោតអ្នកណា ទស្សនៈខ្លួនរាល់ថ្ងៃគិតថាអ្នកណាដែលគ្រប់គ្រង អ្នកណាធ្វើឲ្យខ្ញុំរស់នៅ បានផ្ទះបានសំបែងប៉ុណ្ណេះខ្ញុំអត់ភ្លេចគេដែរ តែខ្ញុំមិនទៅប្រឆាំង អត់ទៅថាឲ្យអ្នកណា អត់ទេ អាហ្នឹង គឺថាមិនទៅតិះទៀនគេ មិនទៅរិះគន់គេនាំឲ្យវាសៅហ្មងក្នុងចិត្តទេ គិតតែព្រលឹមឡើងការងារខ្លួនយើងបានហើយ គេធ្វើអីជារឿងរបស់គេ សព្វថ្ងៃគិតតែប៉ុណ្ណឹង ។

កុសលៈ ចុះសព្វថ្ងៃរដ្ឋាភិបាលមុនដំបូងសន្យាថា ពេលដែលធ្វើសមាហរណកម្មហើយ គឺមិនមានការផ្តន្ទាទោសទេ ដូចលោក អៀង សារី ជាដើម ។ ប៉ុន្តែក្រោយមកចាប់ មិនអីចឹងពូ

សឿនៈ បាទ ។

កុសលៈ មុនដំបូងអត់ខិនទោសឲ្យ គោលនយោបាយរាជរដ្ឋាភិបាល គឺថាអត់ខិនទោសឲ្យ យើងចូលទៅ យើងផ្សះផ្សារជាតិតែមួយទៅ ដាក់អាវុធ ដល់ពេលចូលទៅឥឡូវចាប់ដូច្នេះហាក់ដូចជាមានការផ្ទុយទៅអ៊ីដែលសន្យាពីមុន មិនអីចឹងពូ? លោកពូជ្រាបស្រាប់ហើយមុនដំបូងសន្យាអត់មានការចាប់អីទេ ប៉ុន្តែដល់ក្រោយមកឥឡូវមានបង្កើតតុលាការ ហើយដូចមានការចាប់ដូច អ៊ំ ខៀវ សំផន ដូចចាប់អ្នកផ្សេងទៀតដូចមានកា រំដើបរំដួលអីចឹងតើលោកពូយល់ថាតុលាការហ្នឹងវាប៉ះពាល់ដល់ការផ្សះផ្សារជាតិដែរ ឬទេ? មិនអីចឹងពីមុនមកសន្យាថាចូលមកលើកលែងទោសអស់ហើយ គោលនយោបាយផ្សះផ្សារ ដល់ក្រោយមកថ្មីៗនេះ លោកពូមានតាមដានអីចឹង មានការកាត់ ទោសមេៗ ដូច ឌុច កាត់

ហើយ ។ ចូលដល់ណាទៀត គាន្ធន ជា, ខៀវ សំផន, អៀង សារី, អៀង ធីរិទ្ធ ប្រពន្ធគាត់៤រូប ហើយលឺល្បៀង១ថាចង់បន្តទៀត ០០៣ ណាទៀត ។ អីចឹងខ្ញុំសួរ លោកពូធ្វើអីចឹងប៉ះពាល់ដល់ការផ្សះផ្សារដែលទេ? ធ្វើ អីចឹង?

សឿនះ រឿងហ្នឹងវាប៉ះវាចេះតែប៉ះហើយ អាហ្នឹងជាទស្សនះរបស់អ្នកគេដឹកនាំផ្សេង១ តែ យើងជាប្រជាពលរដ្ឋធម្មតា ការសន្យាចេះតែថា វាមានខុសមានត្រូវ តែខ្ញុំមិនចូល ចិត្តទៅខាងណា ឬក៏អន់ចិត្តទៅខាងណាទេ អាហ្នឹងផ្សះផ្សារតាមតែស្រេចជារឿងរបស់ គេទៅ ខ្ញុំមានតែអីចឹង មិនបានទៅគិតអីវែងឆ្ងាយដល់ថ្នាក់ហ្នឹងទេ ។

កុសលះ ពូដែលតាមដានទេ? តាមដានពីតុលាការ?

សឿនះ មិនទេ មិនដែលចាប់អារម្មណ៍ផង ។

កុសលះ ប៉ុន្តែធ្លាប់លឺទេ?

សឿនះ ធ្លាប់លឺ ថ្ងៃណាដើរចំទៅគេបើកវិទ្យុប៉ុស្តិ៍អាស៊ីសេរី ប៉ុស្តិ៍ស៊ីធីអិន ប៉ុស្តិ៍អាមេរិច លឺ កាត់ទោស គិតទៅកាត់ទោសមិនដឹងថាយ៉ាងណា កាត់ក៏តុលាការចេញរូបទៅហើយ មិន កាត់ក៏តុលាការចេញរូបហើយ រឿងហ្នឹងតវ៉ាក៏មិនបានផលប្រយោជន៍អី គិតទៅគ្មាន កុំ ទៅគិតគូររឿងរបស់គេ គិតតែខ្លួនឯងឲ្យព្រលឹមឡើងរស់បានហើយ និយាយថាអីចឹង ចុះ ។

កុសលះ ដូចពូនិយាយថាបារម្ភបើបន្តទៅទៀត លើសពី០០២ តើអាចមានប៉ះពាល់ទេ? មាន ការរំជើបរំជួលទេ?

សឿនះ មិនដឹងយ៉ាងម៉េច ។

កុសលះ ចេះតែកាត់តទៅទៀត?

សឿនះ កាត់តទៅទៀតហ្នឹងវាអាចប៉ះពាល់ខ្លះដែរ ជាទស្សនះប៉ុន្តែ ។

កុសលះ ចិត្តលោកពូវិញចង់ឲ្យមានតុលាការហ្នឹង ឬមិនចង់ឲ្យមានតុលាការហ្នឹងកើត?

សឿនះ ទេ បើនិយាយពីផ្សះផ្សារ បើមានតុលាការបានន័យថាវាមានជម្លោះ បានមាន តុលាការមិនថាអីចឹង បើផ្សះផ្សារចិត្តខ្ញុំមិនចង់ឲ្យមាន ប៉ុន្តែបើមានទៅហើយ មិនចង់ណា បើមានរួចទៅហើយ ។

កុសលះ តែមិនចង់ឲ្យមានតទៅទៀត ។

សឿនះ បាទ វាថាមិនចង់ឲ្យមានតទៅទៀត ។

កុសលះ ពូមានតាមដានដឹងអីខ្លះដែរ? ដូចថាតាមវិទ្យុ លឺអីខ្លះពីតុលាការ? ដូចថាពូយល់ថា តុលាការហ្នឹងមានប្រយោជន៍អីខ្លះ? ព្រោះគេចំណាយលុយអស់រាប់រយលានខ្ញុំចេះតែ

ឆ្ងល់ ។ តើវាមានប្រយោជន៍អីខ្លះ ដូចលោកពូអត់បានតាមដានផង វាមានប្រយោជន៍អីខ្លះ គេចំណាយលុយអស់រាប់លាន ហើយតុលាការបំរើប្រយោជន៍អ្នកណា ខ្ញុំសួរដូចឆ្ងល់ ។

សឿនៈ បើដូចខ្ញុំគិត ខ្ញុំថាមានចំណាយច្រើនហើយ វាមានផលប្រយោជន៍របស់គេ ប៉ុន្តែយើងអត់បានតាមដានគេបានយើងមិនដឹង ខ្ញុំដូចតែគ្នា ខ្ញុំមិនដឹង មិនដឹងផលប្រយោជន៍ទៅខាងណា មិនដឹងជាខាងណាអ្នកធ្វើ ដល់អីចឹងលឺតែគេថា កាត់ទោសអ្នកនេះម្តងហើយកាត់ទោសអ្នកនោះទៀត ដល់អីចឹងកាត់អីក៏ញ៉យម្ល៉េះ អ្នកណាពីដើមម៉ិញ និយាយរួមអ្នកដែលកើតពីឆ្នាំ៧០ ប្តូក៏៧៣-៧៤ អ្នកណាក៏ខ្មែរក្រហមដូចតែគ្នាសម័យហ្នឹង គ្រាន់តែថាមួយដំណាក់ៗ ។

កុសលៈ សម្តេច ហ៊ុន សែន ក៏ខ្មែរក្រហម?

សឿនៈ បាទ ។ មានយូរ មានឆាប់ ។

កុសលៈ មានចូលមុនចូលក្រោយ?

សឿនៈ បាទ ។

កុសលៈ មានអ្នកផ្តាច់ខ្លួន ។

សឿនៈ មានអ្នកផ្តាច់ខ្លួន មានអ្នកផ្តាច់អហាំងការ មានអ្នកសមាហរណ៍ ។

កុសលៈ អីចឹងទាក់ទងនឹងការទម្លាក់កំហុសហ្នឹង កន្លែងហ្នឹងវាសំខាន់ទាក់ទងការផ្សះផ្សារដូចពូថា ម៉ិញតុលាការហ្នឹងច្បាស់ជាមានផលប៉ះពាល់ខ្លះហើយ វាមិនអត់ទេមិនអីចឹង មានការរំដើបរំជួលក្នុងភូមិ កាត់ទោសហ្នឹងកាត់ទោសគំរិតណា? ការទទួលខុសត្រូវដល់កំរិតណា? ឥឡូវមានការរំដើបរំជួលថាមានតទៅទៀត ដូចពូថាអីចឹងអ្នកខ្លះបារម្ភដែរ បញ្ហាអស់ហ្នឹង ចេះតែតទៅទៀតទៅមិនដឹងកាលណាចប់ វាចេះតែមានការគុំគួន ។

សឿនៈ បាទ ។

កុសលៈ ហើយកាលលោក ឌុច ពូស្គាល់លោកឌុច ទេ?

សឿនៈ លឺតែឈ្មោះទេ ។

កុសលៈ គាត់ជាប្រធានអឹស-២១ នៅគុកទួលស្លែង ។ ពូដែលទៅទួលស្លែងទេ?

សឿនៈ អត់ទេ ។

កុសលៈ ពូដែលទៅភ្នំពេញទេ?

សឿនៈ មិនដែលទៅទេ ។

កុសលៈ គេថាគាត់ក៏ជាមេនៅទួលស្លែង មន្ទីរស-២១ហ្នឹង គាត់ថាគាត់ធ្វើតាមបញ្ជាគេដែរ ។

សឿនៈ	រឿងហ្នឹងច្បាស់ហើយសម័យហ្នឹង ទាំងគេទាំងខ្ញុំ ខ្ញុំមិនធ្វើគេ ក៏គេធ្វើខ្ញុំ ដល់អីចឹងមនុស្ស យករស់រានខ្លួន ដល់ធ្វើទៅវាប៉ះពាល់ វាមានការខុសម្នាងត្រូវម្នាង ប៉ុន្តែគ្រាន់តែថា អ្នកដែលទៅមុនវាផុតបាត់ទៅ វានៅអ្នកក្រោយ ដល់អីចឹងទៅអាអ្នកក្រោយវាគង់តែទៅដូចគ្នា តែវាពិបាកអាទាក់ទាមអីចឹង បើអ្នកមុនៗ

កុសលៈ	ចុះអ្នកធ្វើតាមបញ្ជាគេគួរតែយកមកកាត់ទោសដែរ? គួរទទួលទោសដែលអត់?

សឿនៈ	មិនដឹងត្រង់ហ្នឹងៗ

កុសលៈ	ដូច ឌុច គាត់ថាគាត់ធ្វើតាមបញ្ជាគេទេ តែឥឡូវគេកាត់ទោសគាត់ៗ ពូយល់ថាអ្នកដែលគ្រាន់តែធ្វើតាមបញ្ជាគេ គួរតែទទួលទោសដែលអត់?

សឿនៈ	បើនិយាយមែនទែនបើតាមទស្សនៈរបស់ខ្ញុំ វាមិនស្រណុំ វាបទបញ្ជាអ្នកណាមួយដែលហ៊ានប្រឆាំងនឹងបទបញ្ជាៗ

កុសលៈ	ជំនាន់ហ្នឹងគ្មានអ្នកណាដែលហ៊ានប្រឆាំងទេ?

សឿនៈ	បាទៗ

កុសលៈ	បើយើងមិនធ្វើគេ គេធ្វើយើងហើយ?

សឿនៈ	បាទៗ ដល់អីចឹងបើគិតទៅវាសមឲ្យមានអ្នកគេប្រើឲ្យធ្វើសោះ ដល់ទទួលទោសដូចតែ គ្នា អីចឹងពិបាកសន្និដ្ឋានណាស់ៗ

កុសលៈ	មេដឹកនាំគួរតែទទួលទោសអត់? អ្នកដែលមេគេ?

សឿនៈ	អ្នកបញ្ជាផ្ទាល់ហ្នឹង ធម្មតាទឹកវាមិនដែលហូរបញ្ច្រាសអូរទេ វាតែងតែហូរមកបណ្ដោយអូរ តែមានពេលខ្លះគ្រាន់តែថាមកតិច ឬមកច្រើន តែតាមទស្សនៈរបស់ខ្ញុំ អ្នកដែលបញ្ជាមានខុសហើយ មិនដឹងខុសប្រភេទណា គេកាត់ទោសសមរម្យ តែអ្នកមិនបាននេះហើយ មកបញ្ជាឲ្យគ្នាធ្វើជាគ្នាពិបាកដែរ អីចឹងកាត់ទោសជារឿងផ្សេង អាហ្នឹងទស្សនៈខ្ញុំៗ

កុសលៈ	ចុះសរុបមករបបឆ្កួតកាត់របបពាឆ្នាំ រហូតដល់សមាហរណកម្ម ក្នុងជំនាន់ពាឆ្នាំពូយល់ថាពូជាជនរងគ្រោះ ឬក៏ថាជនបដិវត្តន៍ធ្វើតាមតែគេប្រាប់ៗ

សឿនៈ	និយាយពីបុគ្គលខ្ញុំជាជនរងគ្រោះហើយ អាហ្នឹងធ្វើតាមបទបញ្ជាគេដដែល យើងមិនទៅម៉េចនៅក្នុងរបប បើគេប្រើហើយយើងមិនទៅ

កុសលៈ	ធ្វើតាមបញ្ជាគេរហូត?

សឿនៈ	តាមបញ្ជាគេៗ

កុសលៈ អីចឹងសរុបមកទាក់ទងនឹងរឿងផ្ទះផ្សារហ្នឹង លោកពូថាតាមខ្ញុំយល់លោកពូថា ចង់ឲ្យឃើញមានមេដឹកនាំយកមកកាត់ទោស ប៉ុន្តែឈប់ត្រឹមហ្នឹង ត្រឹម០០២ទៅកុំឲ្យមានតទៅទៀត។

សឿនៈ កុំឲ្យមានតទៅទៀតទៅ។

កុសលៈ ឧបមាថាយកគាត់ទៅដាក់ទោស តើគាត់គួរទទួលទោសធ្ងន់ទេ គាត់ថាគាត់អត់បានធ្វើ ផង គាត់ថាអ្នកក្រោមជាអ្នកធ្វើ បើ តាឌួន ជា អត់ដែលសម្លាប់មនុស្សណាទេ មិនដែលធ្វើអីផង អ្នកខាងក្រោមជាអ្នកធ្វើ។ អីចឹងអ្នកណាជាអ្នកធ្វើ?

សឿនៈ អាហ្នឹងហៅថាម្យ៉ាងម្នាក់ទៀតហើយ គេឆ្លើយយករួចខ្លួនគេ ប៉ុន្តែនិយាយរួមយើងមិនដែលគិតឲ្យឆ្ងាយទេ យើងគិតត្រឹមគ្រួសារតូច កូនខូច ឬក៏កូនមិនខូច មិនមែនមកពី កូនទេ សំខាន់មកពីអ្នកអប់រំ ឪពុកម្តាយហ្នឹងហើយ មេផ្ទះហ្នឹងហើយ វាមិនដែលកូនកើតមកវាធំបេះកាន់កាំភ្លើងមុនឪនោះទេ។

ប្រពន្ធៈ កុំនិយាយម៉ែឪអ្នកឲ្យកូន។

សឿនៈ អាហ្នឹងហើយ បានថាវាផលប្រយោជន៍អាហ្នឹងជារឿងផ្សេងទេ។ អាហ្នឹងយកពីសង្គម គេសង្គមមុនមានម៉ាណាលក់។

កុសលៈ ឃើញនារីស្អាតមិនទៅញ៉ែផង។

សឿនៈ មិនហ៊ានមើលមុខគេផង។

កុសលៈ ខុសសីលធម៌។

សឿនៈ ខុសសីលធម៌ឥឡូវ។

កុសលៈ លោកពូចង់ឲ្យមេដឹកនាំទទួលទោសកំរិតធ្ងន់បំផុត តិច ឬក៏ច្រើន?

សឿនៈ និយាយពីឲ្យពួកគាត់ទទួលទោស ពីដើមម៉ិញរបបផ្តាច់ការវាសំណាំដែល ប៉ុន្តែវាមានហៅថាអង្គការសិទ្ធមនុស្ស ឲ្យសមរម្យតែតុលាការគេកាត់ទោស គេវិនិច្ឆ័យទៅចុះ។

កុសលៈ ស្រេចលើតុលាការ?

សឿនៈ ស្រេចទៅលើតុលាការ។

កុសលៈ ពូជឿថាតុលាការហ្នឹងអាចផ្តល់យុត្តិធម៌ឲ្យទាំងសងខាងទេ?

សឿនៈ ខ្ញុំថាអាចមាន។

កុសលៈ ហេតុអីបានពូយល់ថាអាច?

សឿនៈ ព្រោះក្នុងប្រទេសកម្ពុជាមានអង្គការសិទ្ធមនុស្សចុះមកច្រើន។

កុសលៈ ពូជឿជាក់លើអន្តរជាតិ លើអង្គការសិទ្ធមនុស្សច្រើន?

សឿនៈ បាទ ដល់អីចឹងគេមិនមែនឲ្យភាគីទាំងសងខាង ខាងណាធ្ងន់ ឬខាងណាស្រាល វាគិតទៅស្មើរតែគ្នា ។

កុសលៈ ពូដែលគិតថាចង់ឲ្យដើម្បីការផ្សះផ្សារ ពូចង់ឲ្យសង្គមបច្ចុប្បន្នបំភ្លេចអតីតកាលចោលទេ

សឿនៈ បាទ ទស្សនៈខ្ញុំចង់ឲ្យភ្លេចចោលអស់ទៅ ។

កុសលៈ តិច ឬច្រើន? ភាគរយ?

សឿនៈ ភាគរយ ឲ្យភ្លេចអស់ទៅ កុំឲ្យគិតអតីត ។

កុសលៈ លោកពូមានការសប្បាយចិត្តទេ បានដឹងថាគេយកមេដឹកនាំរបបពាឆ្នាំហ្នឹង មកកាត់ទោស ? លោកពូសប្បាយចិត្តដែលទេ?

សឿនៈ ធម្មតា ។

កុសលៈ តិច ឬច្រើន?

សឿនៈ មធ្យម មិនអរពេក ហើយមិនខឹងពេក ។

កុសលៈ តុលាការជារឿងមួយល្អ ឬយ៉ាងម៉េច?

សឿនៈ ដូចថាមិនមែនតែម្នាក់ទេ មានមេធាវីពងខ្លួន វាមិនល្អពេក អាក្រក់ពេកទេ ។

កុសលៈ ធម្យម?

សឿនៈ មធ្យមដូចគ្នា ។

កុសលៈ ពូជឿលើកម្មផលទេ? ដូចមេៗអស់ហ្នឹង គាត់ទទួលទោសដោយសារតែកម្មផលរបស់គាត់?

សឿនៈ កម្មផលដែលគាត់សាង បើនិយាយពីធម៌ព្រះ ។

កុសលៈ ពូជឿតិច ឬច្រើន?

សឿនៈ និយាយរួមមធ្យមដែលហ្នឹង គាត់ធ្វើបានច្រើនក៏បាបច្រើន គាត់ធ្វើបានមធ្យមក៏បានមធ្យម អាហ្នឹងជារឿងកម្មផលរបស់គាត់ទៅចុះ ។

កុសលៈ លោកពូជឿថាតុលាការហ្នឹងអាចជួយផ្សះផ្សារ សង្គមយើងបានទេមើលទៅ? ផ្សះផ្សាររឿងជនរងគ្រោះ និងអ្នកដែរ?

សឿនៈ ខ្ញុំគិតសង្ឃឹមពាក់កណ្ដាល ។

កុសលៈ មធ្យម?

សឿនៈ មធ្យមដែរ ។

កុសលៈ ហេតុអីមិនបានទាំងអស់?

សឿនៈ មិនបានទាំងអស់ នឹកឃើញថាខ្លាចភាគីទាំងសងខាងមិនទាន់បញ្ចប់ ចេះតែបន្តទៅទៀត អីចឹងគិតថាពាក់កណ្តាលទៅមធ្យម ។

កុសលៈ អីចឹងបានន័យថាអាចផ្សះផ្សារបាន បើយើងមិនបន្តទៅទៀត ។

សឿនៈ បាទ ។

កុសលៈ បន្តកាត់ទៅទៀតវាប៉ះពាល់ការផ្សះផ្សារ?

សឿនៈ បាទ ។

កុសលៈ យើងត្រូវគិតពីអតីតកាល រំលឹកឡើងវិញ? គួរយើងរំលឹកឡើងវិញទេ ពីអតីត កាល?

សឿនៈ ដឹងអី ។

កុសលៈ តិច ឬច្រើន មិនគួរ?

សឿនៈ មិនគួរ ពីអតីតកាលចាស់ហ្នឹង?

កុសលៈ បាទ ។

សឿនៈ មិនគួរឲ្យរំលឹកឡើងទេ វាផុតហើយឲ្យវាផុតទៅចុះ ។

កុសលៈ រំលឹកឡើងវិញវាប៉ះពាល់?

សឿនៈ រំលឹកឡើងវិញនាំតែសៅម៉ង ក្នុងអារម្មណ៍ថាបែកចែក ភ្លេចឲ្យវាភ្លេច ។

កុសលៈ លោកពូឆ្លើយថា លោកពូមិនសូវមានចំណាប់អារម្មណ៍ទៅលើតុលាការហ្នឹងទេ ហេតុអី លោកពូ? ដោយសារមិនតាមដាន មិនចាប់អារម្មណ៍?

សឿនៈ មិនបានតាមដាន មិនបានចាប់អារម្មណ៍ឲ្យច្បាស់លាស់ អត់មានអីស្តាប់ហ្នឹងគេ ។

កុសលៈ ទី១ អត់មានអីស្តាប់ ។ ឬមួយវាមិនសូវមានប្រយោជន៍?

សឿនៈ មិនសូវមានប្រយោជន៍ដល់ខ្លួនឯង បើគិតមែនទែនទៅថាអាត្មានិយមទៅចុះ គិតតែ ផលប្រយោជន៍ គិតតែខ្លួនឯង មិនបានគិតដល់អ្នកណា ។

កុសលៈ រវល់ការងារ?

សឿនៈ រវល់ការងារពេក ព្រលឹមចេញ ព្រលប់ចូល ស្រែចម្ការយើង ដល់ផលប្រយោជន៍ យើង គេអ្នកធំអីចឹង ទស្សនៈខ្លួនឯងស្រេចតែគាត់ចុះ ក្នុងគាត់ ។

កុសលៈ ទុកអាហ្នឹងឲ្យរដ្ឋាភិបាលចុះ?

សឿនៈ ទុកឲ្យរដ្ឋាភិបាលគ្នាគាត់ចុះ យើងគិតតែស្រែ គិតតែចម្ការ កាលយើងដេកព្រៃបានធ្វើ ស្រែ ធ្វើចម្ការណា ។

កុសលៈ ឥឡូវមានស្ថិរភាពប៉ុណ្ណឹងហើយ?

សឿនៈ ឥឡូវគេឲ្យធ្វើពេញចឹងហើយ យើងធ្វើមិនបានហូបខ្លួនឯងវាអន់ពេក ។

កុសលៈ អីចឹងដូចថាថ្នាក់ដឹកនាំកំរិតណាទៅដែលទទួលខុសត្រូវក្នុងរបបហ្នឹង នៅក្នុងរបប៣ឆ្នាំ ទី១ មេៗរាល់ថ្ងៃហ្នឹង ទី២ថ្នាក់ដឹកនាំតំបន់ ទី៣មេស្រុក ឬមេសន្តិសុខ ទី៤មេសហករណ៍ ឬកម្មាភិបាលគ្រប់ប្រភេទ?

សឿនៈ បើថានេះឲ្យរដ្ឋាភិបាលកាត់តុលាការគេគិតកំពូលៗ ហើយកុំឲ្យមានតទៅទៀតដែរ ។ ហ្នឹងដល់គាត់ចូលតុលាការស្រេចលើផលកម្មរបស់គាត់ ។

កុសលៈ ដូចករណី លោក ឌុច គាត់ធ្វើតាមបញ្ជាគេ លោកពូគិតថាគាត់គួរតែធ្វើតាមបញ្ជា ពេលហ្នឹង ឬគាត់គួរតែបដិសេធន៍ប្រឆាំង ភៀសខ្លួនរត់ចេញពីប្រទេស? ឧបមាថា លោក ឌុច ពេលហ្នឹងគាត់ធ្វើតាមបញ្ជាគេដែរ តែមានជំរើសផ្សេងៗ ទី១ត្រូវតែ គោរពនិងអនុវត្តតាមបទបញ្ជា ទី២គាត់អាចបដិសេធន៍ប្រឆាំង ជំទាស់នឹងអង្គការ ទី៣ ភៀសខ្លួនរត់ទៅក្រៅប្រទេស ឬក៏មានចម្លើយផ្សេងទៀតពេលហ្នឹង?

សឿនៈ ពេលហ្នឹងខ្ញុំគិតថា ផ្នែកនយោបាយវាចូលជ្រួតជ្រាបខ្លាំង ហ្នឹងតាមទស្សនៈរបស់ខ្ញុំ ដល់វាចូលជ្រួតជ្រាបខ្លាំងពេកគេចអត់បានទេ បើគេចបានដូចគ្នាហ្នឹងគេប៉ុណ្ណឹងដែរ ។

កុសលៈ ប៉ុន្តែសុខចិត្តគោរពអនុវត្តតាម ដោយសារគាត់ចូលខ្លាំង ។

សឿនៈ ហ្នឹងហើយគាត់ចូលគាត់ខ្លាំង ។

កុសលៈ តាមមើលគាត់អ្នកចេះដឹងម្នាក់ដែរ ពេលនិយាយទៅ គាត់ដូចដឹងច្រើន គាត់អ្នកច្បាស់ លាស់រឿងគោលនយោបាយ ចេះបារាំងទៀតតាហ្នឹង ។ ពូថាគាត់មិនអាចគេចខ្លួនបានទេ ពេលហ្នឹង?

សឿនៈ មិនមែនថាគេចមិនបានទេ បើគាត់គេចបានដូចគ្នា ។

កុសលៈ តែគាត់មិនចង់ ។

សឿនៈ គាត់មិនចង់ ។

កុសលៈ អីចឹងសរុបសេចក្តី តើពូយល់យ៉ាងណាចំពោះទង្វើរបស់ ឌុច ពេលហ្នឹង? ត្រឹមត្រូវ ខុស ប៉ុន្តែពិបាកយល់ ខុសដោយសារកន្លែងគាត់កាប់កាន់ហ្នឹងមានការធ្វើទារុណកម្ម និងកាប់ សម្លាប់ ឬខុសដោយសារអំពើហ្នឹងវាខុសសីលធម៌ ។

សឿនៈ ខុសសីលធម៌ត្រង់អំពើដែលយើងធ្វើ ។

កុសលៈ ខុសប៉ុន្តែគាត់ពិបាកយល់?

សឿនៈ ពិបាកយល់ខ្លួនគាត់ ទៅខាងនេះវាខុស ដឹងតែផ្លូវហ្នឹងវាខុសហើយ ប៉ុន្តែនៅតែធ្វើ ។

កុសលៈ សកម្មភាពរបស់ ឌុច មានភាពត្រឹមត្រូវប្រសិនបើមនុស្សដែល ឌុច បញ្ជាឲ្យសម្លាប់ហ្នឹង ជាសត្រូវរបស់រដ្ឋ, សកម្មភាពប្រឆាំងនឹងអង្គការដូចជាការលួចរបស់រដ្ឋ, ទី៣ភ្នាក់ងារ

សម្ងាត់របស់សត្រូវ កាសេបេ-សេអ៊ីអា ឬសត្រូវវណ្ណៈនាយទុនមូលធន បើសិនអ្នកដែលសម្លាប់ហ្នឹងជាសត្រូវរបស់រដ្ឋ តើអ៊ីដែលគាត់ធ្វើហ្នឹងត្រឹមត្រូវទេ?

សឿន: ហ្នឹងជាសត្រូវរបស់រដ្ឋ បើគាត់សំរេចចិត្តថាធ្វើមិនខុសទេ។

កុសលៈ ព្រោះសត្រូវរបស់រដ្ឋ?

សឿន: គាត់អ្នកគ្រប់គ្រង ឋានៈរបស់គាត់ប៉ុណ្ណឹងដែរ ដល់ប៉ះសត្រូវធ្វើ ហ្នឹងមិនខុសទេ។

កុសលៈ ភ្នាក់ងារសំងាត់ផ្សេងៗក៏ដោយ?

សឿន: ភ្នាក់ងារសម្ងាត់ដែលបំបែកបំបាក់រដ្ឋគេហ្នឹង។

កុសលៈ សំនួរបន្តទៀតសុំពូផ្តល់ចម្លើយពី១-៥ដែរ ១តិច ៥ច្រើន។ អ្នកដែលទទួលបញ្ជាធ្វើទារុណកម្មនោះបានប្រព្រឹត្តិអំពើដែលត្រឹមត្រូវ ប្រសិនបើពួកគាត់ អ្នកដែលជិនាទំហ្នឹងគាត់ចេះតែធ្វើ ទី១បើគាត់មិនធ្វើទេ គេធ្វើបាបគ្រួសារយើង។

សឿន: អាហ្នឹងអីចឹងហើយ។

កុសលៈ ត្រឹមត្រូវ?

សឿន: ត្រឹមត្រូវ ឯកភាព យើងមិនធ្វើគេក៏គេធ្វើយើង។

កុសលៈ គ្រួសាររបស់គាត់ហ្នឹងមានគ្រួសារ?

សឿន: បាទ។

កុសលៈ ពួកគាត់មិនត្រូវចាត់ទុកជាអ្នកបដិវត្តន៍ល្អម្នាក់?

សឿន: បាទ។

កុសលៈ ពួកគាត់មិនធ្វើហ្នឹងចាត់ទុកថាមិនមែនជាអ្នកស្នេហាជាតិ? មិនស្មោះត្រង់ហ្នឹងអង្គការ

សឿន: មិនស្មោះត្រង់នឹងអង្គការទេ។

កុសលៈ អ៊ីចឹងមនុស្សម្នាក់មិនអាចទទួលខុសត្រូវ ចូលក្នុងគោលការណ៍ទទួលខុសត្រូវ យើងអាចសន្និដ្ឋានថា មនុស្សម្នាក់មិនអាចទទួលខុសត្រូវ ចំពោះអំពើដែលខ្លួនបានដឹង តែខ្លួនមិនបានប្រព្រឹត្តិនោះទេ ត្រឹមត្រូវទេ?

សឿន: បាទ។

កុសលៈ មនុស្សម្នាក់មិនអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលខ្លួនគ្រាន់តែធ្វើតាមបញ្ជាគេនោះទេ? លោកពូឆ្លើយហើយ យើងគ្រាន់តែធ្វើតាមបញ្ជាគេមិនត្រូវទទួលខុសត្រូវទេ?

សឿន: បាទ ទទួលខុសត្រូវអី យើងធ្វើតាមគេ គេប្រាប់ឲ្យយើងធ្វើ គេជាគ្រូយើង គេជាឪពុកម្តាយយើង យើងធ្វើតាម។

កុសលៈ ធ្វើហ្នឹងយើងខុសហើយ។

សឿនៈ ខុសហើយ ដឹងថាខុសហើយ ។

កុសលៈ សមហេតុផល ព្រោះអង្គការគេបង្គាប់ឲ្យគាត់ធ្វើអីចឹង?

សឿនៈ អង្គការគំរូវឲ្យធ្វើអីចឹង ដឹងតែខុសហើយ បើយើងប្រឆាំងក៏មិនកើត ប្រឆាំងប៉ះខ្លួន ឯង អីចឹងត្រូវតែធ្វើ ។

កុសលៈ ក្រោយមក ឌុច គេកាត់ទោសឲ្យគាត់ជាប់៣៥ឆ្នាំ ដោយសារតែគាត់គេដាក់គុកគាត់ ប៉ុន្មានឆ្នាំហើយ គេបន្ថយសល់១៩ឆ្នាំវិញ លោកពូគិតថាការកាត់ទោស១៩ឆ្នាំហ្នឹងផ្តល់ យុត្តិធម៌ចំពោះគាត់ទេ?

សឿនៈ ខ្ញុំនិយាយលើកមុន តុលាការមិនអាក្រក់ពេក ក៏មិនល្អពេកដែរ យុត្តិធម៌តែងមាននៅលើ បុគ្គលរបស់មនុស្សយើងដែលបានប្រព្រឹត្តិ ។

កុសលៈ អីចឹងមធ្យម?

សឿនៈ មធ្យម ។

កុសលៈ តែលោកពូយល់ស្របទេ យល់ស្របខ្លាំងដែលដាក់ទោសគាត់ជាប់១៩ឆ្នាំហ្នឹង ។

សឿនៈ អាយុគាត់ប៉ុន្មានហើយ?

កុសលៈ ហុកសិបជាងហើយ ។

សឿនៈ ១៩ឆ្នាំទៀតចិតសិប ។

កុសលៈ ប៉ុន្តែគេថាគាត់ទទួលខុសត្រូវស្ថាប័នមួយ ស-២១ ស្លាប់មនុស្សច្រើន ១៨ពាន់នាក់ អ្នកដែលស្លាប់ជំនាន់ហ្នឹងក្រោមការគ្រប់គ្រងរបស់គាត់ នៅភ្នំពេញ មួយម៉ឺនបួនពាន់ នាក់ ប៉ុន្តែគាត់ជាប់គុក១៩ឆ្នាំ តែគាត់ថាគាត់ធ្វើតាមបញ្ជាគេដែរ?

សឿនៈ បើនិយាយមែនទែនថាធ្វើតាមបញ្ជាគេសមរម្យហើយ នៅសល់១៩ឆ្នាំទៀត ។

កុសលៈ សមហេតុផល?

សឿនៈ សមហេតុផល ហុកជាងហើយ នៅសល់១៨ឆ្នាំទៀត ចិតបួន បើនិយាយអ្នកធ្វើស្រែ ចម្ការដូចខ្ញុំ បើជីវភាពគេមានធូរធារ គេមិនឆាយឆាប់ដែរ ដូចស្រែចម្ការដូចខ្ញុំទៅមិនដល់ ទេ ឆាប់មុនហើយ ។

កុសលៈ ឧបមាថាលោកពូជាចៅក្រមនៅតុលាការចុះ ឧបមាអីចឹង តើលោកពូគួរតែកាត់ទោស មេដឹកនាំទាំង៤រូបបែបណា? ចំលើយទី១ មិនបាច់កាត់ទោសទេ ដើម្បីសន្តិភាពនិង ផ្សះផ្សារ ទី២កាត់ទោសកំរិតស្រាល ទី៣ កាត់ទោសសមល្មម ទី៤កាត់ទោសឲ្យធ្ងន់ ចម្លើយមួយណាពូយក បើពូជាចៅក្រម ។

សឿនៈ ប្រសិនបើខ្ញុំជាចៅក្រម បើចង់ឲ្យប្រទេសជាតិផ្សះផ្សារជាប់ គឺត្រឹមមធ្យមបានហើយ

កុសលៈ គាត់ល្អមៗ?

សឿនៈ ល្អមៗ មិនរាក់ពេកហើយមិនជ្រៅពេក។

កុសលៈ មួយទៀត លោកពូក៏ឆ្លើយដែលថាមេដឹកនាំជំនាន់៣ឆ្នាំហ្នឹង ត្រូវទទួលខុសត្រូវចំពោះផលប៉ះពាល់ទាំងឡាយណាដែលស្ថិតនៅក្រោមការបញ្ជារបស់គាត់ គាត់ជាមេបា ពូ ឯកភាពទេ?

សឿនៈ បាទ។

កុសលៈ ច្រើន តិច?

សឿនៈ ល្អមដែរ។

កុសលៈ មេដឹកនាំរបប៣ឆ្នាំហ្នឹងត្រូវកាត់ទោស ដោយមិនអាស្រ័យលើចេតនារបស់ពួកគាត់នោះទេ តែត្រូវកាត់ទោសទៅលើលទ្ធផល អ្វីដែលគាត់បានធ្វើ?

សឿនៈ បាទ។

កុសលៈ គាត់ថាធ្វើហ្នឹងដើម្បីប្រទេសជាតិល្អ ធ្វើដើម្បីល្អ អីចឹងគួរតែកាត់ទោសតាមចេតនារបស់គាត់ ឬតាមសកម្មភាពជាក់ស្តែង? វាប៉ះពាល់មានការកាប់សម្លាប់ អីចឹងកាត់ទោសគេបែបណា ចេតនា ឬតាមសកម្មភាព?

សឿនៈ តាមចេតនាដែលគាត់ធ្វើល្អ បើមិនអីចឹងប៉ះពាល់ផលអាក្រក់ ហ្នឹងជារឿងផ្សេង។

កុសលៈ គាត់ក៏មិនចង់អីចឹងដែរ?

សឿនៈ គាត់ក៏មិនចង់អីចឹងដែរ។

កុសលៈ លោកពូគិតថាមេដឹកនាំដូចលោកតា ប៉ុល ពត ហ្នឹងគាត់គួរតែដឹងថាគោលនយោបាយរបស់គាត់ ដូចជាការជម្លៀសប្រជាជន ការបង្ខិតបង្ខំឲ្យធ្វើការហួសកំលាំង មហន្តរាយដល់ប្រទេសជាតិ គាត់គួរតែដឹងទេពេលហ្នឹង?

សឿនៈ ដឹង។

កុសលៈ គិតថាគាត់ដឹងទេ?

សឿនៈ ដឹង។

កុសលៈ លោកពូយល់ថាគ្រប់គ្នាសុទ្ធតែអនុវត្តតាមច្បាប់ ដូចថាលោកពូផ្ទាល់អនុវត្តន៍ច្បាប់ក្នុងរដ្ឋាភិបាល ក្នុងអង្គការពេលហ្នឹង គ្រប់គ្នាត្រូវតែអនុវត្តន៍តាម?

សឿនៈ គ្រប់គ្នាត្រូវតែអនុវត្តន៍ អត់មានប្រឆាំងបានទេ។

កុសលៈ ពេលហ្នឹងលោកពូមានអារម្មណ៍ថាខ្លួនគិតទៅរបបហ្នឹង គាំទ្រមាគ៌ាពេលហ្នឹងល្អទេ? គេបង្រៀនមក?

សឿនៈ វិភាគទៅវាមិនល្អប៉ុន្មាន មិនអាក្រក់ប៉ុន្មានដែរ ។

កុសលៈ ល្អយ៉ាងម៉េច អាក្រក់យ៉ាងម៉េចទៅពូ ប្រៀបធៀបឲ្យខ្ញុំដឹងផង ។

សឿនៈ ល្អគាត់ដឹកនាំហ្នឹងវាត្រូវហើយ ធ្វើការរួមគ្នាវាត្រឹមត្រូវ តែនៅទូទាំងប្រទេសឲ្យហូបបាយរួម វាប៉ះពាល់ផលប្រយោជន៍ទស្សនៈរបស់មនុស្សម្នាក់ៗ គ្មានអ្នកណាចង់ទៅហូបបាយទាំងហ្វូងទេ សូម្បីតែក្នុងគ្រួសារ៧-៨នាក់ នៅឈ្លោះប្រកែកគ្នា ទំរាំតែមួយសហករណ៍ៗរាប់ពាន់ រាប់ម៉ឺននាក់ ហ្នឹងទស្សនៈខ្ញុំថាល្អមិនក៏ល្អ អាក្រក់ក៏មិន អាក្រក់ពេកល្មម ។

កុសលៈ ខ្ញុំឆ្ងល់ថាពេលហ្នឹងម៉េចមានអត់បាយ ប្រទេសយើងធ្វើស្រែគ្រប់តែគ្នា ហេតុអីអត់បាយខ្ញុំអត់យល់ ។

សឿនៈ មិនដឹងដែរ ស្រែបើនិយាយពីធ្វើស្រែពីមួយហិចតាសុទ្ធតែ៣-៤តោន តែប្រជាជនហូបបបរ ខ្ញុំឆ្ងល់នោះៗ ចង់សួរក្លួយឯង ។

កុសលៈ មីងឆ្ងល់ទេម៉េចអីចឹង?

ប្រពន្ធៈ ខ្ញុំឆ្ងល់ដែរ ខ្ញុំនៅភ្នំពេញលីអង្ករដាក់សុទ្ធតែឡាន សុទ្ធតែកាណូត ម៉េចអត់ឲ្យបាយហូប

កុសលៈ អ្នកមីងឃើញអង្ករច្រើនទេពេលហ្នឹង?

ប្រពន្ធៈ អង្ករច្រើន បញ្ចេញតាមទូរទេះភ្លើង ។

កុសលៈ យកទៅណា?

ប្រពន្ធៈ មិនដឹងយកទៅណា ដល់ពេលនេះឲ្យហូបនំប័ុង ។

កុសលៈ ដែលសួគេទេ ថាយកអង្ករទៅណា?

ប្រពន្ធៈ មិនដែលហ៊ានសួរគេ គេឲ្យហូបនំប័ុងមួយក្នុងមួយថ្ងៃ មួយពេលមួយកំណាត់ ហើយពូៗលីអង្ករ ពោះបាក់ដល់ឆ្អឹងខ្នង នំប័ុងមួយដែរ មួយកំណាត់មួយពេល ។

កុសលៈ អង្ករហ្នឹងវាយកទៅណាទៅ?

ប្រពន្ធៈ មិនដឹងយកទៅណា ។

កុសលៈ បើ៣តោន ហើយធ្វើស្រែទូទាំងប្រទេស ។

សឿនៈ បើធ្វើតែប្រជាពលរដ្ឋខ្ញុំមិនថាទេ កងទ័ពដូចខ្ញុំក៏ធ្វើស្រែដូចគ្នាដែរ ហើយប្រលងប្រណាំងជាមួយសហករណ៍ដូចគ្នា ធ្វើស្រែណា៎ ។

កុសលៈ សុទ្ធតែប្រលងប្រណាំងគ្នាជិនាន់ហ្នឹង?

សឿនៈ បាទ មុំខាងត្បូងអន្លង់វែង សុទ្ធតែស្រែកងទ័ពហើយ ទៅមើលភ្លឺមានអាភ្លោះ អត់ទឹកបាចមនុស្សមានម៉ាស៊ីនណាជិនាន់ហ្នឹង ។

កុសលៈ នៅតែអត់បាយ?

សឿនៈ នៅតែអត់បាយ បបរគល់ចេកដដែល បានគិតថាខ្ញុំឆ្ងល់ពេកមិនដឹងយកទៅណា យកទៅដុតចោលក៏មិនឃើញមានភ្នក់ភ្លើង ។

កុសលៈ ពេលហ្នឹងមិនដែលហ៊ានសួរគេ?

សឿនៈ មិនដែលទេ ។

ប្រពន្ធៈ មិនដែលហ៊ានសួរគេខ្លាចវាស់ គេវ៉ៃផុយសឹងអី ។

សឿនៈ ដួងគោះម៉ឺងបានបបរមួយវែកហ្នឹង ហុតតែ២ត្រូកអស់ហើយ ហីទៅ មានអីមានទៅហ៊ានហូបផ្លែអីខុស បើនិយាយពីដំណាំវិញ ដំឡូង ចេក ឯងដាំបានដូចគ្នា តែអត់ហ៊ានមានពេលកាប់ទេ ដាំខ្លួនឯងក៏មិនហ៊ានកាប់ខ្លួនឯង កាប់ទាល់តែមានច្បាប់ទម្លាប់ កាប់យកទៅដាក់រួមហូបទាំងអស់គ្នា ហូបបានតែផ្លែឈើព្រៃ ផ្លែគុយ គ្មានអ្នកណាដាក់រួមទេ ហូបបានហ្នឹងនិយាយពីកង់ទ័ព បើប្រជាពលរដ្ឋនៅតាមសហករណ៍មិនដឹងម៉េចទេ មិនបានឆ្លងកាត់ផងមិនដឹងគេពិបាកជាងខ្ញុំ ឬខ្ញុំពិបាកជាងគេ ។

កុសលៈ និយាយពីការលំបាក ត្រឡប់មកសម័យនេះ បន្ទាប់ពីសមាហរណកម្មមក លោកពូទុកចិត្តអ្នកជិតខាង ទុកចិត្តលើការដឹកនាំ ភូមិ ឃុំដែរទេ?

សឿនៈ រាល់ថ្ងៃទុកចិត្តច្រើនដែរ ។

កុសលៈ ចុះអ្នកជិតខាងអីក៏មានការទុកចិត្តគ្នាទៅវិញទៅមក សាមគ្គីគ្នា?

សឿនៈ សាមគ្គីគ្នាទៅ គេអត់គេមករកយើងទៅ យើងអត់យើងទៅរកគេទៅ ។

កុសលៈ តើបច្ចុប្បន្ននេះលោកពូ-អ្នកមីងមានម្ចាស់ការលើខ្លួនឯង ម្ចាស់ការក្នុងការចិញ្ចឹមជីវិតការរស់នៅ តើមានម្ចាស់ការជាងពីមុន ឬយ៉ាងម៉េច?

សឿនៈ សព្វថ្ងៃនេះដូចថាអត់មានរកអីខុសពីរបស់ហូបទេ ម្ចាស់ការខ្លួនឯងទុកឲ្យកូនចៅ ដីស្រែទុកទៅដែលខំតាំងពីណាណី ដុតពីនោះមកបាតដៃទេ មកពីផ្ទះទំរាំបានប៉ុណ្ណេះមិនងាយទេលោកអើយ មានទៅចោលអត់ប្រយោជន៍ទេ ។

កុសលៈ តើលោកពូមានទំនុកចិត្តលើរាជរដ្ឋាភិបាលបច្ចុប្បន្នដល់កំរិតណាដែរ ក្នុងការផ្ដល់យុត្តិធម៌ដល់ប្រជាជន តើមានភាពយុត្តិធម៌ទេរដ្ឋាភិបាលបច្ចុប្បន្ន? ពី១-៥ ១តិច ៥ ច្រើន តើរដ្ឋាភិបាលមានភាពយុត្តិធម៌ដល់កំរិតណា? ពូនិយាយឲ្យត្រង់ ។

សឿនៈ ខ្ញុំទុកចិត្តរដ្ឋាភិបាលត្រង់ថា ដែលខុះខាតគាត់មានជំនួយមកខ្លះ បើយើងធ្វើអ្វីមួយមិនប៉ះពាល់ដល់រាជរដ្ឋាភិបាល យើងធ្វើអីក៏បានតាមចិត្ត ខ្ញុំទុកចិត្តត្រង់ថាគាត់មិនគាបសង្កត់អីប្រជាពលរដ្ឋ រកអីក៏រកទៅ កុំឲ្យតែរករបស់ខុសច្បាប់ របស់ខុសច្បាប់មាន

មាត្រាគេចែងហើយ ច្បាប់គេមានហើយ យើងរកខុសច្បាប់ធ្វើអី ធ្វើស្រែមិន ខុសច្បាប់ ដាំដំឡូងមួយ-ពីរវេរ មួយហិច មិនខុសច្បាប់ ក្រុមហ៊ុនគេចេញមកឲ្យដាំ គេមិនទិញយើង ដាំធ្វើអី ជ្រូកស៊ីឯង ។

កុសលៈ ប្រសិនបើជាគោលនយោបាយក្នុងស្រុកភូមិហ្នឹងមក ពូយល់ថាមិនត្រឹមត្រូវ ពូហ៊ាន ជំទាស់ទេ?

សឿនៈ ទេ ។

កុសលៈ ឧបមាថាគោលនយោបាយរដ្ឋាភិបាលមកវាមិនត្រូវទៅហ្នឹងអ៊ី ពូយល់ថាមិនត្រឹមត្រូវ ពូហ៊ានជំទាស់ទេ រិះគន់កែលំអរដែលទេ?

សឿនៈ អត់ខ្លាចទេ បើថាគោលនយោបាយមកពីនោះផ្សេង មកដល់នេះផ្សេង ជំទាស់ដែរហ្នឹង ជំទាស់ដែលហ្នឹង ផលប្រយោជន៍មិនមែនចេះតែធ្វើតាមទេ ។

កុសលៈ ហើយសព្វថ្ងៃលោកពូគាំទ្រឲ្យមានការចូលរួមសកម្ម នៅក្នុងគោលនយោបាយអភិវឌ្ឍន៍ ស្រុក-ភូមិយើងដែលទេ? មានដែលចូលរួមដូចថាធ្វើផ្លូវថ្នល់ ក្នុងសហគមន៍ ក្នុងភូមិ មានដែលចូលរួមប្រជុំដែលទេ?

សឿនៈ ចូលរួមប្រជុំ ធ្វើសាលា ។

ប្រពន្ធៈ ឈប់ធ្វើទាហាន ។

កុសលៈ លោកពូឈប់ឆ្នាំណា?

សឿនៈ ឈប់ឆ្នាំ២០០៨ ។

កុសលៈ ថ្មីៗនេះ ។

ប្រពន្ធៈ កាលវ៉ៃព្រះវិហារនៅវ៉ៃហ្នឹង ។

កុសលៈ នៅទៅវ៉ៃដែរ ។

សឿនៈ បាទ ។

កុសលៈ ដល់ហើយតស៊ូឡើង ។ អាជ្ញាធរភូមិស្រុកអីអត់មានបញ្ហាទេ ពូមានទំនុកចិត្ត?

សឿនៈ បាទ ។

កុសលៈ ច្រើន តិច?

សឿនៈ មធ្យមដែល ។

កុសលៈ ហេតុអីបានមធ្យម?

សឿនៈ ខ្ញុំមិនទុកចិត្តដែលហ្នឹង ។

កុសលៈ ហេតុអី?

សឿនៈ ផលវិបាកហៅទៅលើដូចមិនស្រួលដែល ។

កុសលៈ ឧទាហរណ៍ជាក់ស្តែង?

សឿនៈ បាទ ឧទាហរណ៍ ហោប៉ៅចំហលើ យើងតូចតាចរកមិនបាន គេធំរកបាន របស់អីក៏ដោយ ។

កុសលៈ ចង់និយាយថាអាជ្ញាធរឥឡូវក៏មានបញ្ហាពុករលួយខ្លះៗដែរ ចង់និយាយអីចឹង?

សឿនៈ បាទ មានខ្លះវាមិនដែលអត់ទេ មានខ្លះអត់ខ្លះ តែវាមានភាគតិច វាអត់ភាគតិច វាមានគុណធម៌ភាគច្រើន សំរាប់ប្រជាពលរដ្ឋអាចមានទំនុកទុកចិត្តបាន មិនដល់មួយរយ ភាគរយក៏កៅសិបដែរយើងអាចរស់បាន អាចពឹងពាក់គេបាន ។

កុសលៈ ចុះជំនឿលើព្រះពុទ្ធសាសនា ពូឧស្សាហ៍ទៅវត្តទេឥឡូវ?

សឿនៈ យាយទៅ តែខ្ញុំមិនដែលបានទៅវត្តហ្នឹងគេទេ ធ្វើទាហាន សឹកពីទាហានមិនដែលហ៊ានចូលវត្ត ។

កុសលៈ ពូជឿលើព្រះពុទ្ធសាសនា តិច ឬច្រើន?

សឿនៈ ព្រះពុទ្ធសាសនាយើងជឿសំខាន់ខ្លួនយើង អនុវត្តន៍មិនខុសពីច្បាប់ទេ និយាយមែនទែនព្រះពុទ្ធសាសនាគឺច្បាប់ហ្នឹងហើយ យើងធ្វើអំពើល្អវាបានផលល្អ ធ្វើអាក្រក់បានផលអាក្រក់ បាបក៏ដូចគ្នាវាកើតមកពីផលល្អ និងផលអាក្រក់ បើយើងធ្វើផលល្អវាដែល បាបបើយើងធ្វើផលអាក្រក់វាបាបហើយ វាដូចតែគ្នាបើគិតទៅ ។

កុសលៈ គោរពតាមសីល៥របស់ព្រះពុទ្ធ មិនលួច មិនសម្លាប់ មិនបោកប្រាស់ ពូជឿទៅលើសីល៥របស់ព្រះពុទ្ធ ។

សឿនៈ ហ្នឹងហើយ ជឿអីចឹងឯង អានេះដូចតែសីលធម៌ដូចតែគ្នា បើនិយាយពីពាក្យសំរាយមកវិញ គេហៅថាសីលធម៌ទាំង៥ប្រការហ្នឹងទៅ យើងកាន់កុំលួច កុំផឹក កុំស៊ី កុំទៅ ប្លន់ កុំទៅជេរម្តាយគេ កុំទៅជាន់ដីគេ កុំទៅលួចរបស់គេ យើងបានប៉ុណ្ណាហូបប៉ុណ្ណឹងយើងឃ្លានយើងអត់យើងសុំគេទៅ ។

កុសលៈ កាតព្វកិច្ចរបស់ពូចំពោះក្រុមគ្រួសារ តើមានសារសំខាន់ជាងខ្លួនលោកពូ រាល់ថ្ងៃ នេះ?

សឿនៈ បាទ ។

កុសលៈ សំខាន់?

សឿនៈ សំខាន់នៅក្នុងគ្រួសារហ្នឹងឯង ខ្លួនឯងចំណាស់នេះហើយ ។

កុសលៈ ចុះចំពោះសង្គម និងខ្លួន អ្នកណាសំខាន់ជាង? គ្រួសារ និងសង្គម?

សឿនៈ គ្រួសារហ្នឹងឯង ។

កុសលៈ តើរដ្ឋាភិបាលបច្ចុប្បន្នផ្ដល់នូវសេចក្ដីសុខ ដល់លោកពូ និងក្រុមគ្រួសារបានកំរិតណាដែរ? ១តិច ៥ច្រើន?

សឿនៈ បាន ។

កុសលៈ បាន៣?

សឿនៈ មិនមែន៣ទេ ។

កុសលៈ ៤មធ្យម? លើសមធ្យម? ល្អដែរ?

សឿនៈ ល្អដែរ ។

កុសលៈ តើរដ្ឋាភិបាលបានផ្ដល់សន្ដិសុខដល់ភូមិ-ឃុំ ដូចថាឲ្យមានការសុខស្រួលជាមួយគ្នាក្នុងភូមិបានកំរិតណាដែរ?

សឿនៈ បានកំរិតមធ្យមដែរ ។

កុសលៈ រឿងការពារប្រទេស តើរដ្ឋាភិបាលបច្ចុប្បន្នការពារប្រទេសជាតិបានកំរិតណា? ១តិច ៥ច្រើន? ពូធ្លាប់បានទៅការពារប្រាសាទព្រះវិហារ?

សឿនៈ គិតទៅរាជរដ្ឋាភិបាលយើងអត់ធ្មត់ខ្លាំងបំផុត គឺចង់រកសុខសន្ដិភាព ដូចខ្ញុំថាហ្នឹងឯង អីចឹងបានទុកចិត្តរដ្ឋាភិបាល ៤ចុះ ។

កុសលៈ តើលោកពូមានជំនឿទៅលើប្រព័ន្ធយុត្តិធម៌ ដូចថាតុលាការខេត្ត-ស្រុកអីជាដើម ជឿទេ ជឿថាមានយុត្តិធម៌? ប្រព័ន្ធយុត្តិធម៌ តុលាការ ឧបមាថាពូមានរឿងក្ដី មានរឿងអ្នកណាគេយកដី ហើយពូទៅតុលាការ ពូជឿជាក់ថាតុលាការរាល់ថ្ងៃហ្នឹង អាចរកយុត្តិធម៌ឲ្យលោកពូបានទេ?

សឿនៈ អាហ្នឹងពិបាកដែរ គិតទៅក្រជឿតែខ្ញុំទៅ កុំឈ្លោះនឹងស្រី កុំក្ដីនឹងចិន ។

កុសលៈ អីចឹងវាតិច?

សឿនៈ ភាគតិចណាស់ខ្ញុំមិនសូវជាជឿប៉ុន្មានទេ ព្រោះយើងអ្នកក្រ តែអត់លុយហើយធ្វើអីមិនបានទេ គេដាក់តែមួយប្រាំវមកផងឹតមុខឈឹង មិនផងឹតមុខខ្លួនឯងក៏ផងឹតមុខ តុលាការយូរៗកោះហៅម្ដងទៀត មិនធ្លាប់មានប្ដឹងផ្ដល់អី តែតាមខ្ញុំសង្កេតមើលវា អីចឹងមែន ។ អាហ្នឹងមិនមែនមកពីរាជរដ្ឋាភិបាលទេ ។

កុសលៈ មកពីមនុស្ស បុគ្គល ។

សឿនៈ មកពីបុគ្គលដែលអនុវត្តន៍ខុសរឿង ។

កុសលៈ អីចឹងខ្ញុំត្រឡប់ទៅរបបពន្លាំវិញ ប្រសិនបើគេថាខ្ញុំធ្វើតាមបញ្ជា ក្នុងរបបនោះពីព្រោះខ្ញុំជឿមាគ៌ាបដិវត្តន៍របស់អង្គការ ថាមាគ៌ាមួយត្រឹមត្រូវ តើពូឯកភាពទេ?

សឿនៈ ទូទៅប្រជាពលរដ្ឋនៅក្នុង គេហៅថាប្រែប្រួលពីសង្គមមួយទៅសង្គមមួយ អ្នកណាក៏គេមានជំនឿដែរ គេមានជំនឿ មានទុកចិត្តដែរ ប៉ុន្តែដល់ផ្ទុយទៅវិញវាខុសរឿង ដល់អ៊ីចឹង វាមិនអស់ទុកចិត្តទេ តែធ្វើម៉េចបើទៅហើយ ។

កុសលៈ ក្នុងរបបហ្នឹងក្នុងនាមជាជនបដិវត្តន៍តស៊ូ ជាទាហានម្នាក់ ខ្ញុំគាំទ្រអង្គការ គោលនយោបាយរបស់អង្គការគឺដើម្បីឲ្យមានសង្គមនិយម ធ្វើឲ្យប្រទេសក្លាយជាប្រទេសបដិវត្តន៍ រឹងមាំ និងជាគំរូដល់ពិភពលោកបានឃើញ ជំនាន់ហ្នឹងលោកពូជឿថាអ៊ីដែល ប្រឹងធ្វើដើម្បីឲ្យប្រទេសយើងក្លាយជាប្រទេសសង្គមនិយម មានបដិវត្តន៍រឹងមាំទេ ជំនាន់ហ្នឹង?

សឿនៈ បើតាមទស្សនៈខ្ញុំជឿពាក់កណ្ដាល មិនជឿពាក់កណ្ដាល ឥឡូវមិនបាច់គិតអី យើងគិតថាមនុស្ស ហើយយើងគិតតែក្រុមគ្រួសារតូច ទំរាំតែបានល្អមិនងាយទេ តែងតែប៉ះពាល់ខ្លះ ប៉ុន្តែច្រើនណាស់ ចុះទំរាំតែកែប្រែប្រទេសជាតិ អ៊ីចឹងបានគាត់ថាអ្នកណាមិនចូកមិនចែវ កុំយកជើងរាទឹក ភាគច្រើនណាស់អ្នកដែលជ្រះស្រឡះ ភាគតិចអត់ទេ កែប្រែសង្គមពិបាកណាស់ ។

កុសលៈ អ៊ីចឹងពូមិនសូវជាជឿប៉ុន្មានទេ?

សឿនៈ មិនសូវជាជឿប៉ុន្មាន តាមមើលទប់មិនរួច ព្រោះមិនមែនមានតែយើង វាមានគេដែរ

កុសលៈ ពេលនោះពូមានគិតថាបើសិនជាមិនដើរតាមគោលនយោបាយ របស់បក្សជំនាន់ហ្នឹង ឬមាគ៌ាបដិវត្តន៍ជំនាន់ហ្នឹងទេ គឺថាខ្មាំងក្នុងជួរនិងក្រៅជួរ អាចនឹងបំភ្លេចបំផ្លាញប្រទេសយើង ដូចជាវណ្ណៈអធន ដូចពួកខ្មាំង ពួកវៀតណាមជាដើម ពូបារម្ភទេពេលហ្នឹង?

សឿនៈ បារម្ភ ។

កុសលៈ បើសិនជាមិនធ្វើតាមទេ ។

សឿនៈ បើមិនធ្វើតាមទេ ជាខ្មាំងក្នុងជួរហើយ អ៊ីចឹងវាចូលទៅខ្សែបង្កប់លិចកើត ។

កុសលៈ បង្កប់ស៊ីរូងផ្ទៃក្នុង?

សឿនៈ បង្កប់ស៊ីរូងផ្ទៃក្នុង ។

កុសលៈ បើសិនបើខ្ញុំគោរពតាមបញ្ជាថ្នាក់លើ គ្រួសារខ្ញុំនឹងរួចផុតពីគ្រោះភ័យ ត្រឹមត្រូវទេ?

សឿនៈ បាទ តែបើពិចារណាខ្លួនឯងក៏មិនត្រូវប៉ុន្មានដែរ វាខុស ។

កុសលៈ ខុសយ៉ាងម៉េច?

សឿនៈ ខុសពីសង្គមមុន យើងធ្លាប់នៅសង្គមមុន ដល់អ៊ីចឹងរបបនេះផ្សេង របបនោះផ្សេង ឧទាហរណ៍ពីដើមម៉ិញយើងធ្លាប់ចាយលុយមិនថាអ៊ីចឹង ដល់មកហូបរួមអ៊ីចឹងទៅវា ពិបាកមនុស្សម្នាក់ៗ គេអ្នកមានគេមិនចង់ហូបរួមដូចយើងទេ អ្នកក្រទេដែលធ្វើបាន ។

កុសលៈ ប៉ុន្តែចេះតែគោរពតាមបញ្ញាទៅឲ្យរួចផុតពីគ្រោះភ័យ ។

សឿនៈ អ្នកមានគេបន់ឲ្យតែមានសង្គ្រាមទៀត សំរាប់គេអ្នកមាននោះ ។

កុសលៈ ត្រឡប់មករាជរដ្ឋាភិបាលបច្ចុប្បន្នវិញ ពូសុំផ្តល់ចំលើយពី១-៥, ១មិនត្រឹមត្រូវទាល់តែសោះ, ៥ ត្រូវខ្លាំងណាស់ ។ អ៊ីដែលខ្ញុំពឹងចង់បានបំផុតពីរាជរដ្ឋាភិបាលបច្ចុប្បន្ននោះគឺថា ប្រជាពលរដ្ឋទាំងអស់អាចប្រកបរបរ និងមានជីវភាពល្អ ហើយមានសុវត្ថិភាព ។

សឿនៈ អាហ្នឹងត្រឹមត្រូវហើយ ។

កុសលៈ ពូឲ្យលេខប៉ុន្មាន?

សឿនៈ ត្រឹមត្រូវ ។

កុសលៈ ៤ ត្រូវ, ៥ត្រូវខ្លាំងណាស់ ។

សឿនៈ ៥ទៅ ។

កុសលៈ មួយទៀតទី២ ប្រសិនបើលោកពូមានភាពជឿងឆ្ងល់ពីបទបញ្ញារបស់រដ្ឋាភិបាល អ៊ីដែលល្អបំផុតសំរាប់លោកពូគឺថាត្រូវធ្វើអ៊ីៗ ដែលរដ្ឋាភិបាលតំរូវឲ្យ ដើម្បីរួចផុតពីគ្រោះថ្នាក់ ។ មានន័យថា រដ្ឋាភិបាលដាក់គោលមាគ៌ាមក ទោះបីពូយល់ថាត្រូវ ឬខុស ក៏ដោយ ដើម្បីសេចក្តីសុខត្រូវតែធ្វើតាម ឬពូហ៊ានជំទាស់ដែរ?

សឿនៈ បើមាគ៌ាដែលដាក់មក រាជរដ្ឋាភិបាលដាក់មកប្រជាពលរដ្ឋមានទំនុកទុកចិត្តថាមាគ៌ាហ្នឹងត្រឹមត្រូវ មានសេចក្តីសុខហើយ ហ្នឹងធ្វើតាម ប៉ុន្តែចេញមកតែរាងមិនទំនងក៏អាចហ៊ានជំទាស់ដែរ បើយើងធ្វើមិនត្រឹមត្រូវ ព្រោះយើងមានពិសោធន៍វាខុសម្តងហើយកុំឲ្យខុសទៀត ។

កុសលៈ មូលហេតុមួយសំរាប់គាំទ្ររដ្ឋាភិបាលនោះថាខ្ញុំ មិនចង់ឲ្យសង្គមជាតិគ្មានអ្នកគ្រប់គ្រង និងអស្ថិរភាពតទៅទៀត? ត្រឹមត្រូវទេ?

សឿនៈ បាទ ។

កុសលៈ ពូចង់ឲ្យសង្គមមានស្ថិរភាព?

សឿនៈ ឲ្យមានស្ថិរភាពដូចសព្វថ្ងៃហ្នឹងទៅ ឲ្យវាល្អប្រសើរ ។

កុសលៈ គាំទ្រឲ្យរាជរដ្ឋាភិបាលកាត់បន្ថយឥទ្ធិពលជនជាតិបរទេស? តើពូគាំទ្រឲ្យកាត់បន្ថយជនជាតិបរទេសទេ?

សឿនៈ ឥទ្ធិពលជនជាតិបរទេស ដូចជាពួកអរិយធម៌ខាងសិល្បៈអីចឹង?

កុសលៈ រួមទាំងអ្នកមករកស៊ី មកយកដីធ្លី បរទេសចូលមកប្រទេសយើងច្រើនណាស់មិនអីចឹង ចូលមកសេរី តើលោកពូគាំទ្រឲ្យកាត់បន្ថយឥទ្ធិពលជនជាតិហ្នឹងទេ ជនជាតិបរទេស ដូចជាជនជាតិចិន វៀតណាម ជាដើម ។

សឿនៈ អាហ្នឹងបើចិតខ្ញុំចង់ឲ្យកាត់បន្ថយខ្លះដែរហ្នឹង ។

កុសលៈ តិច ឬច្រើន?

សឿនៈ មធ្យម ។

កុសលៈ ពូមានបារម្ភទេ?

សឿនៈ បារម្ភឥឡូវ ដីធ្លីបារម្ភខ្លាចថាបើដី ឧទាហរណ៍ថាក្នុងផ្ទះខ្ញុំ ក្នុងគ្រួសារខ្ញុំមាន៩ហិចតា ឬ១០ហិចតា បើជាគោលដៅរបស់រដ្ឋចំតែម្តង អាហ្នឹងគ្មានបញ្ហាទេ ខ្លាចតែអ្នកបង្វែរពីរដ្ឋមក តម្លៃថោកបំផុតជាងរដ្ឋាភិបាល ជិទាស់ដែលហ្នឹង បារម្ភរឿងហ្នឹងរាល់ថ្ងៃ ខ្លាចគេយកជាអីចឹង ។

កុសលៈ គោលបំណងនៃបង្កើតច្បាប់ កុំឲ្យប្រជាជនប្រព្រឹត្តិបទឧក្រិដ្ឋ ត្រឹមត្រូវទេ?

សឿនៈ ត្រឹមត្រូវហើយ ។

កុសលៈ ជនជាតិបរទេសឥឡូវច្រើនដែរ មានចិនមកយកដី ក្រុមហ៊ុនមកយកដីរាប់ពាន់ហិចតា មិនដឹងយ៉ាងម៉េចទេ ដល់អីចឹងទៅប្រទេសយើង ។

សឿនៈ ប្រទេសយើងពិបាក យូរៗទៅអត់មានខ្មែរ ។

កុសលៈ ខាងនោះមកពីសៀម ។

សឿនៈ អត់មានខ្មែរទេសញ្ញាតិគេអស់ ។

កុសលៈ ជម្លោះថ្មីៗ ពួកវៀតណាមថាពួកសៀមវាឆ្កួត អញយកតែដីស្រែ ។ ពួកសៀមចង់បានដុំថ្ម វៀតណាមថាពួកសៀមល្ងង់ អញយកតែដីស្រែខ្មែរទេ ។

សឿនៈ ថ្មស៊ីអីកើត ។

កុសលៈ អានោះយកដីស្រែពីខាងនោះមកវិញ ។

សឿនៈ ត្រូវមានអីខាត រាល់ថ្ងៃវាឈ្លោះចង់បានប្រាសាទតាមាន់ ប្រាសាទតាក្របី ដុំថ្ម ប្រាសាទព្រះវិហារមានស្អីសុទ្ធតែដុំថ្ម ដាំស្អីកើតត្រង់ហ្នឹង ជីកត្រង់សេមិនមុតផង កូន៣ដើមហ្នឹងមិនដឹងប៉ុន្មានសតវត្សមកហើយ ដៃ្លឈោងដល់មិនទៅលេបផង កនៅប៉ុនភ្លៅឥឡូវខ្ញុំ ទៅនៅ៣ខែ សម័យវ៉ៃមុនដំបូងមួយឆ្នាំ កាលហ្នឹងអត់ទាន់ផ្ទុះ ដល់ផ្ទុះបានមួយឆុល ផ្ទុះហើយកាលប្រាសាទលានឥន្ទ្រី បាញ់គ្នាបែកបាក់វង្វេងប៉ុន្មានយប់ប៉ុន្មាន ថ្ងៃគ្នា ចង់លេងជាមួយខ្មែរម៉េចបាន លេងមិនបានទេ ពិបាកដែរ រឿងធ្វើអីមិនដឹងទេ បើថារឿងធ្វើ

សន្ត្រា ។ម បើថាបាញ់ពិបាកដែរ បើថាធ្វើអីផ្សេងៗមិនដឹងទេ ដាទឹក លុយដាទឹកប្រាក់អី អាហ្នឹងខ្មែរក្របែបយក ។

កុសលៈ ត្រឡប់ទៅរបបពន្ធារិញលោកពូ ចង់សួរនិយមន័យជាជនបដិវត្តន៍ល្អមួយរូប គឺជាមនុស្ស មកពីគ្រួសារកសិករ ជាជនបដិវត្តន៍ពិតប្រាកដ និងជាជនស្នេហាជាតិហ៊ានពលីជីវិត ប្រឆាំងនឹងខ្មាំងសត្រូវ ត្រឹមត្រូវទេ?

សឿនៈ ត្រឹមត្រូវហើយ ។

កុសលៈ លោកពូយល់ថាខ្លួនឯងជាជនបដិវត្តន៍ល្អម្នាក់ទេ ជំនាន់ហ្នឹង?

សឿនៈ បាទ គេហ៊ានធ្វើប៉ុណ្ណឹងគេល្អហើយ ល្អត្រឹមត្រូវហ៊ានពលីជីវិតដើម្បីបដិវត្តន៍ហើយអា ហ្នឹងដូចថា យើងបច្ចុប្បន្ននេះ គេហៅហ៊ានពលិជីវិតដើម្បីជាតិ បដិវត្តន៍និងជាតិមិនខុស គ្នា គ្រាន់តែកែប្រែពាក្យសំដីតែប៉ុណ្ណឹង ។

កុសលៈ ត្រូវឲ្យមានការស្មោះត្រង់នឹងអង្គការ អនុវត្តន៍គោលការណ៍របស់អង្គការដោយឥតខ្ចោះ ត្រូវទេ?

សឿនៈ ត្រូវហើយ ។

កុសលៈ ត្រូវហ៊ានលះបង់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ប្រឹងប្រែងធ្វើការដើម្បីប្រយោជន៍សមូហភាព ដូចពូថាកន្លែងហ្នឹង ពូមិនពេញចិត្តដែរ?

សឿនៈ មិនឯកភាពទេ ។

កុសលៈ ម៉េចអីចឹង?

សឿនៈ យករបស់ខ្លួនឯងទៅឲ្យអ្នកដទៃយ៉ាងម៉េចទេ ខំចង់ងាប់ ។

កុសលៈ ជំនាន់ហ្នឹងពូមិនយល់ថាធ្វើសហករណ៍ហ្នឹងល្អទេ?

សឿនៈ ទេ មិនល្អទេ ។

កុសលៈ ម៉េចអីចឹង ដាក់រួម សម្បត្តិរួម?

សឿនៈ គោក្របី អំពែ ខំពីកេរ្តិ៍ម៉ែដូនតា មកដាក់រួម ងាប់គោងាប់ក្របីអស់ ។

កុសលៈ ត្រង់ហ្នឹងមួយពូមិនឯកភាព?

សឿនៈ មិនឯកភាពទេ ។

កុសលៈ ថាមិនល្អ?

សឿនៈ មិនល្អ វាមិនដែលខ្មែរយើងពីណាពីណើមកវាមិនដែល ប្រទេសគេអ្នកដទៃក៏វាមិនអីចឹង ដែរ ទើបតែមានប៉ុន្មានប្រទេសដែលធ្វើហ្នឹង វាដូចថាមិនទំនងបើខ្ញុំ ទស្សនៈខ្ញុំមិនឯកភាព ទេ ។

កុសលៈ លោកពូថារបបពន្ឋាំហ្នឹង លោកពូគាំទ្រ និងគោរពតាមច្បាប់វិន័យរបស់អង្គការជានិច្ច និងប្រតិបត្តិតាមមាគ៌ារបស់បក្សយ៉ាងម៉ឺតម៉ាត់ ត្រឹមត្រូវ?

សឿនៈ បើមិនគោរពវាមិនកើត ។

កុសលៈ អីចឹងពី១-៥ ពូគោរពត្រឹមណាដែរ?

សឿនៈ ធ្វើម៉េចមួយល្មម មួយរស់បាននៅ បានសុខ បានរស់ ។

កុសលៈ ត្រឡប់មកបច្ចុប្បន្នវិញ និយមន័យតួនាទីរបស់ប្រជាពលរដ្ឋល្អមួយរូប គឺជាមនុស្សធ្វើការដើម្បីកសាងកិត្តិនាម និងកេរ្តិ៍ឈ្មោះជាតិកម្ពុជានៅតំបន់ ត្រឹមត្រូវ?

សឿនៈ បាទ ។

កុសលៈ លោកពូធ្វើទាហានដឹងស្រាប់ហើយ រហូតដល់២០០៨ ។

សឿនៈ ធ្វើល្អដាក់ប្រជាពលរដ្ឋទូទៅ ធ្វើល្អបានល្អហើយ ។

កុសលៈ អីចឹងពូទៅការពារតំបន់ព្រះវិហារដែរ? កាលហ្នឹងគេឲ្យទៅការពារប្រាសាទវិហារ កាលហ្នឹង គេឲ្យទៅការពារ?

សឿនៈ បាទ ។

កុសលៈ ចូលរួមវ៉ៃជាមួយពួកថៃកាលហ្នឹង?

សឿនៈ គេមួយគ្រឿងដែរ ខ្ញុំនៅកងពល៤២ ។

កុសលៈ ម៉េចដែលពូកាលហ្នឹង ពេលទៅវ៉ៃពួកថៃហ្នឹង?

សឿនៈ វាមិនហ៊ានផង និយាយភាគច្រើនតំបន់នេះគ្មានទាហានរដ្ឋាភិបាលទេ ពួកឈុតខ្មៅវានិយាយវាថាអត់មានទេ សុទ្ធតែទាហានខ្មែរក្រហមទាំងអស់ ។

កុសលៈ វាខ្លាច វាធ្លាប់ជួបប្រទះពីមុន?

សឿនៈ វាខ្លាច វាធ្លាប់ជួបប្រទះ ដល់អីចឹងមិនដឹងម៉េច ដាក់តែមួយគ្រឿងក៏ស្ងាត់ទៅ ដូចថាមិនចង់ ។

កុសលៈ មួយទៀតប្រជាជនកម្ពុជាដែលល្អមួយរូប គឺជាមនុស្សតែងតែគោរពច្បាប់ និងអាជ្ញាធរមានសមត្ថកិច្ច ពូឯកភាពទេ?

សឿនៈ ឯកភាព ។

កុសលៈ ភាគរយ?

សឿនៈ បាទ បើយើងមិនគោរពសមត្ថកិច្ច អាជ្ញាធរ សង្គម ធ្វើម៉េចកើតជាពលរដ្ឋល្អ ។

កុសលៈ អីចឹងសព្វថ្ងៃពូនឹងធ្វើអ្វីៗទាំងអស់ ដែលរដ្ឋាភិបាលដាក់បញ្ញាឲ្យអនុវត្តន៍?

សឿនៈ បាទ ។

កុសលៈ ក្នុងនាមពូជាជនស្នេហាជាតិ ពូនឹងប្រយុទ្ធប្រឆាំងដើម្បីការពារប្រាសាទ បើសិនជាទាហានថៃចូលមកទៀត ពូហ៊ានទេ?

សឿនៈ ខ្លាចអី ឈប់មិនទាន់បានមួយឆ្នាំផង ។

កុសលៈ ខ្ញុំនឹងតវ៉ាប្រសិនបើរដ្ឋាភិបាលមិនការពារប្រាសាទនេះបាន ពូឯកភាពទេ?

សឿនៈ បាទ មិនដែលលឺប្រាសាទព្រះវិហាររបស់សៀមឯណា លឺតែរបស់ខ្មែរពីណាពីណើ មក ។

កុសលៈ ពួកហ្នឹងចេះតែល្បិចយកទៅណា ។

សឿនៈ ល្បិចលិចកើតឈ្លោះគ្នាក្លឹង ។

កុសលៈ ខ្ញុំប្រឆាំងដាច់ខាតប្រសិនរាជរដ្ឋាភិបាលបំពានលើសិទ្ធរបស់ខ្ញុំ? លោកពូឯកភាពទេ តិច ឬច្រើន?

សឿនៈ ឯកភាពច្រើន ។

កុសលៈ ខ្ញុំនឹងប្រឆាំងដាច់ខាត ប្រសិនបើរដ្ឋាភិបាលបច្ចុប្បន្នបំពានលើសិទ្ធមនុស្ស?

សឿនៈ បាទ ។

កុសលៈ តិច ឬច្រើន?

សឿនៈ មធ្យម ។

កុសលៈ ជិតចប់ហើយ ត្រឡប់មកចុងក្រោយវិញ ខ្ញុំសរុបសេចក្ដីមកទេ ទាក់ទងនឹងការវាយតម្លៃទៅលើផលប្រយោជន៍ដែលភ្ជាប់ទៅនឹងតុលាការ ។ និយាយរួមតុលាការហ្នឹងមានសារសំខាន់អីខ្លះ? តុលាការកាត់ក្ដីខ្មែរក្រហមសព្វថ្ងៃ ទី១អ៊ីដែលខ្ញុំពេញចិត្តចំពោះតុលាការនេះ គឺថាតុលាការបង្កើតនៅក្នុងប្រទេសកម្ពុជា ប្រសិនបើគេបង្កើតនៅប្រទេសក្រៅ គេបង្កើតនៅក្នុងស្រុក ពូពេញចិត្តមួយណាជាង?

សឿនៈ បង្កើតតុលាការកាត់ទោសខ្មែរក្រហមនៅប្រទេសកម្ពុជា ខ្ញុំដូចឆ្ងល់ដែរ តែនិយាយមែនទែនទស្សនៈខ្ញុំកម្ពុជាជាអ្នកខុស មានតែបង្កើតនៅកម្ពុជា នៅបង្កើតប្រទេសគេ ម៉េចកើតបើប្រទេសគេអត់មានខុសផង ប្រទេសគេអត់មានប្រែប្រួលសង្គម ដល់អីចឹងទាល់តែបង្កើតនៅប្រទេសកម្ពុជា ។

កុសលៈ តែវាមានប្រយោជន៍ទេបង្កើតនៅក្នុងស្រុកយើង ។

សឿនៈ មិនដឹង ។

កុសលៈ ពូពេញចិត្តដែលតុលាការហ្នឹងធ្វើនៅស្រុកយើង តិច ឬច្រើន?

សឿនៈ ល្មមដែរ មធ្យម ។

កុសលៈ តុលាការនេះនឹងធ្វើឲ្យប្រទេសកម្ពុជា ក្លាយទៅជាប្រព័ន្ធតុលាការដែលល្អជាងនេះ តុលាការនេះនឹងក្លាយទៅជាតុលាការគំរូ ធ្វើឲ្យប្រព័ន្ធយុត្តិធម៌យើងមានយុត្តិធម៌ ពូ ជឿទេ?

សឿនៈ បាទ ។

កុសលៈ ជឿថាតុលាការអាចធ្វើឲ្យប្រទេសយើងមានប្រព័ន្ធយុត្តិធម៌ល្អជាងមុនទេ?

សឿនៈ មានប្រព័ន្ធយុត្តិធម៌ល្អហ្នឹង បានគេយកមកដាក់កម្ពុជា ហ្នឹងជាគំរូមុនគេ ។

កុសលៈ មានតិច មានច្រើន?

សឿនៈ មធ្យម ។

កុសលៈ តួនាទីរបស់តុលាការហ្នឹងពិតជា មានសារៈសំខាន់ក្នុងការការពារកុំឲ្យមេដឹកនាំប្រទេសទៅអនាគតកុំឲ្យប្រព្រឹត្តិដូចរបបពាធ្នាំទៀត ។ តើពូជឿថាតុលាការហ្នឹងអាចការពារកុំឲ្យអំពើហ្នឹងកើតឡើងទៀត?

សឿនៈ បាទ ។

កុសលៈ តិច ឬច្រើន?

សឿនៈ ច្រើន ។

កុសលៈ ខ្ញុំជឿថាសាលាក្តីជាមធ្យោបាយឲ្យប្រជាជនទទួលបានយុត្តិធម៌?

សឿនៈ បាទ ។

កុសលៈ តិច ឬច្រើន?

សឿនៈ ច្រើន ។

កុសលៈ ខ្ញុំពេញចិត្តដែលតុលាការនេះមានចៅក្រមខ្មែរចូលរួម? តិច ឬច្រើន?

សឿនៈ ច្រើន ។

កុសលៈ វាពិតជាមានសារសំខាន់ដែលតុលាការនេះមានសមាសភាពអន្តរជាតិចូលរួម? ពូចង់ឲ្យជនបរទេសចូលរួមទេតុលាការ?

សឿនៈ ដូចមិនទុកចិត្តពួកបរទេសសោះ ។

កុសលៈ ហេតុអី?

សឿនៈ ពីព្រោះមិនមែនសញ្ជាតិខ្លួនយើង សំខាន់ទឹកលុយ ។

កុសលៈ ពួកហ្នឹងមកចង់បានលុយ?

សឿនៈ ចង់បានលុយ សំខាន់សញ្ជាតិខ្លួនឯង ខ្មែរខ្លួនឯងបានទុកចិត្តខ្មែរខ្លួនឯង បើដល់សញ្ជាតិគេវាមិនត្រូវទេ មិនទុកចិត្ត ប៉ុន្តែមិនមែនមិនទុកចិត្តទាំងស្រុងទេ ទស្សនៈយើងបារម្ភខ្លាចមិនសូវទុកចិត្តប៉ុន្មានទេ ប៉ុន្តែបើវាកើតទៅហើយឲ្យកើតចុះ ។

កុសលៈ ពូនិយាយហើយដើម្បីសន្តិភាព គឺពូឯកភាព កុំឲ្យមានកាត់ក្តីលើសពី០០២ ហ្នឹងឯកភាពខ្លាំង?

សឿនៈ បាទ ។

កុសលៈ ពេលដែលគេធ្វើការរិះគន់ទៅលើតុលាការហ្នឹង ពូដែលលឺគេរិះគន់ដល់តុលាការហ្នឹង ទេ?

សឿនៈ អត់ដែលលឺទេ ។

កុសលៈ បើសិនជាគេរិះគន់តុលាការហ្នឹងពូមានការអន់ចិត្តទេ?

សឿនៈ តួនាទីនេះអត់មានអន់ចិត្តអីទេ ។ បើមើលឃើញជាផ្ទាំង គេពិនិត្យឃើញតុលាការហ្នឹងមិនល្អ គេរិះគន់បែបជាច្រកចេញហើយ ។

កុសលៈ ខ្ញុំគាំទ្រតុលាការនេះទោះបីសារសំខាន់របស់តុលាការនេះ មិនទាន់មានភាពជាក់លាក់ក៏ដោយ ពូឯកភាព ឬមិនឯកភាព? ខ្ញុំគាំទ្រឲ្យតុលាការទោះបីតុលាការមានភាពស្រពិចស្រពិលក៏ដោយ ពូគាំទ្រដែរ? តិច ឬច្រើន?

សឿនៈ ឯកភាព ។

កុសលៈ ពូគាំទ្រតុលាការតិច ឬច្រើន? ពី១-៥?

សឿនៈ មធ្យម ។

កុសលៈ មិនសូវជាគាំទ្រប៉ុន្មាន?

សឿនៈ បាទ ។

កុសលៈ ៣មានន័យថាមិនសូវជាគាំទ្រប៉ុន្មានទេ?

សឿនៈ បាទ ។

កុសលៈ តើលោកពូគិតថាអ្វីដែលកើតឡើងក្នុងរបបពាន្លាំ ពី៧៥-៧៩ហ្នឹង វាជាហេតុការណ៍មួយមិនអាចជៀសវាងបាន ពូគិតថាអ្វីៗដែលកើតឡើងនៅក្នុងរបបពាន្លាំអាចជៀសវាងបានទេ?

សឿនៈ អត់ជៀសបាន ទៅអត់រួច វាទៅរឿងហ្នឹងទៅហើយ យើងធ្វើដំណើរទូកហ្នឹងចេញទៅហើយ មកវិញក៏មិនកើត មិនអាចជៀសបានត្រូវតែទៅ ។

កុសលៈ វាជារឿងមួយគួរឲ្យសោកស្តាយ ប៉ុន្តែយើងត្រូវសំឡឹងមើលទៅអនាគតដោយមិនគិតពីអតីតកាលទៀត?

សឿនៈ បាទ គិតទៅអនាគតខ្ញុំឯកភាព ។

កុសលៈ តិច ឬច្រើន?

សឿនៈ ខ្ញុំឯកភាពច្រើន ។

កុសលៈ ពូមានវិប្បដិសារីទេដែលថាលោកពូបាន ពាក់ព័ន្ធទៅនឹងរបបហ្នឹង?

សឿនៈ មាន ដេកគិត អង្គុយគិត វាមិនសម វាមិនគួរ ដូចថាមិនមានរបបហ្នឹងក៏ដូចថាខ្ញុំមិនបានបែកស្រុកបែកស្រែ បែកភូមិ បែកបងបែកប្អូនអី បើតាមមើលហើយរស់នៅជុំ គ្នាដល់មានរបបហ្នឹងទៅបែកគ្នាទៅទីណាត់ទីណែង អាហ្នឹងទស្សនៈខ្លួនឯងវានឹកឃើញតែរបបហ្នឹងវាអន់ចិត្តដែរ ។

កុសលៈ អ៊ីចឹងលោកពូជឿនូវរឿងរ៉ាវដែលបានកើតឡើង លោកពូជឿថាជំនាន់ហ្នឹងមានការកាប់សម្លាប់អីចឹងមែន?

សឿនៈ មែនទេដឹង ។

កុសលៈ ប្រាប់តាមត្រង់លោកពូជឿដែរ?

សឿនៈ ខ្ញុំជឿថាមានមែន ។

កុសលៈ ហេតុអីបានលោកពូជឿ លោកពូមិនដែលបានឃើញផង?

សឿនៈ ទូទៅអីចឹងហើយ ខ្ញុំជឿថាវាមានមែន ព្រោះឃើញតាមអង្គភាពខ្លះដែលរកមនុស្សមានខុសមានត្រូវអីចឹង ដល់ខុសយកគ្នាទៅធ្វើនេះធ្វើនោះ ដាក់ទោស ឬដាក់ពិន័យ ដូចមិនសមហេតុមិនសមផលទៅ ។

កុសលៈ អ៊ីចឹងលោកពូមានពេលខ្លះមានភាពខ្មាសអៀន សោកស្ដាយ ឬវិប្បដិសារីដែលពាក់ព័ន្ធ នឹងរបបហ្នឹង ពូមានពេលខ្លះមានអារម្មណ៍ខ្មាសអៀនគេទេ ឬយ៉ាងម៉េច?

សឿនៈ វាណាស់ពេកទៅហើយរឿងខ្មាសអៀន ខ្មាសខ្លួនឯង ពីនោះមកសម័យនេះទៅនឹកឃើញខ្មាសក្មេងសារក្រោយ គេរៀន ឯងចាស់ចង់ងាប់មិនបានរៀននៅតែក្នុងព្រៃ គេថាផ្ទះសរសេរ២ មានអីមានតែអង្រឹង ដល់អីចឹងនឹកឃើញកុំតែមានរបបហ្នឹងមក អញមិនដល់ថ្នាក់នេះ មិនស្រួលមានផ្ទះមានសំបែងរស់នៅដូចគេ មានម៉ែមានឪ ស្លាប់ រស់នៅក្នុងក្រុមគ្រួសារខ្លួនឯង ដល់អីចឹងនឹកអន់ចិត្ត ប៉ុន្តែមិននិយាយ និយាយធ្វើអីផង ទៅមិនរួចបានមិននិយាយ ។

កុសលៈ អីចឹងត្រឡប់មកការផ្សះផ្សាវិញ ចំណុចធំ ចំណុចចុងក្រោយ ធ្វើម៉េចឲ្យមានការផ្សះផ្សា? ពេលយើងនិយាយដល់របបពន្លាំហ្នឹង យើងគួរទប់កំហឹងក្នុងចិត្ត?

សឿនៈ បាទ រឿងការផ្សះផ្សាតែកាលកន្លងផុតហើយ ដូចខ្ញុំនិយាយអីចឹង ផុតហើយកុំឲ្យមានវិលើងមក គេថាកុំឲ្យមានលើកទី២ រឿងហ្នឹងទុកក្នុងចិត្តតែខ្លួនយើងទៅចុះ មិនមានគំនុំអីទៀតទេ ឲ្យវាចប់រលាយសាបសូន្យផុតបាត់ចុះ ។

កុសលៈ ជឿលើបុណ្យបាប កម្មពៀរ?

សឿនៈ ជឿលើកម្មពៀរ របស់អ្នកដែលសាងបាប គឺបាបទៅ អ្នកណាដែលសាងល្អ គឺល្អអីចឹង ។

កុសលៈ រាល់ថ្ងៃលោកពូនៅមានការអន់ចិត្ត ឬកំហឹងក្នុងខ្លួន?

សឿនៈ អត់ទេ ។

កុសលៈ គ្រាន់តែមានការសោកស្ដាយបន្តិចបន្តួច?

សឿនៈ ការសោកស្ដាយបន្តិចបន្តួច គ្មានកំហឹងគ្មានអីទេ ។

កុសលៈ ចុះការអត់ទោសឲ្យគ្នាទៅវិញទៅមក លោកពូអ្នកដែលធ្វើខុសឧបមាថាតុលាការមិនបាន កាត់ទោសក៏ដោយ តើលោកពូគិតថាគួរតែមានការសុំទោសទៅវិញទៅមក?

សឿនៈ អីចឹងហើយ ការអត់ឱនទោសហ្នឹង គ្នាក៏គ្នាមិនចង់ នេះជាបទបញ្ញាដូចតែគ្នា យើងក៏មិន ដឹងថាគ្នាធ្វើអីចឹង យើងក៏មិនទៅជាន់គ្នា ថាឲ្យឯងខុសនេះខុសនោះ បេះដឹងអីជាង គេ អាហ្នឹងអត់ឱនឲ្យគ្នាបាន អត់ឱនឲ្យគ្នាទៅ គ្នាក៏មិនចង់ធ្វើដែរ បើនិយាយមែនទែន ទៅ មនុស្សម្នាក់ៗមានអ្នកណាចង់ខុសមិនថាអីចឹង ។

កុសលៈ ប៉ុន្តែធ្វើយ៉ាងម៉េចទៅដើម្បីឲ្យមានការអត់ឱនទោស? ធ្វើម៉េចទៅឧបមា បើជនម្នាក់ៗគេ អ្នកប្រព្រឹត្ដិ ម្នាក់ទៀតជាអ្នករងគ្រោះ ធ្វើម៉េចឲ្យពីរនាក់ហ្នឹងអត់ឱនទោសឲ្យគ្នា ទៅវិញ ទៅមក ។

សឿនៈ អាហ្នឹងទាល់តែមានតុលាការជួយ បើនិយាយមែនទែនទាល់តែមានរដ្ឋាភិបាលកែសំរួល ។

កុសលៈ ឲ្យរដ្ឋាភិបាលចូលរួមកែសំរួល ។

សឿនៈ កែសំរួលអីចឹងទៅ ឲ្យអត់ឱនទោសឲ្យគ្នា ហើយមានពួកអង្គការសិទ្ធមនុស្សអីចឹងគេមក ជួយឯងនេះ ជាសិទ្ធរបស់មនុស្សដូចគ្នា ឲ្យនិយាយរឿងល្អកុំនិយាយរឿងចាស់ហ្នឹង យើង បំភ្លេចរាងខ្លួន ឯងក៏ភ្លេច ខ្ញុំក៏ភ្លេច ។

កុសលៈ ឲ្យស្វែងយល់?

សឿនៈ ស្វែងយល់ពីគ្នាទៅវិញទៅមក សាមគ្គីគ្នាទៅ ។

កុសលៈ ពូដែលធ្លាប់និយាយរឿងសាច់រឿងកើតឡើងប្រាប់កូនចៅពូដែរ? របបពនំ?

សឿនៈ មិនដែលនិយាយផង ខ្ជិលនឹកឃើញវាមិនដឹងទៅហើយ ឲ្យវាមិនដឹងតែម្ដងទៅ មិនដែល និយាយប្រាប់ ។

កុសលៈ អ្នកមីងក៏មិនដែលនិយាយប្រាប់ទេ?

សឿនៈ មិនដែលនិយាយទេ ។

កុសលៈ ឲ្យវាកន្លងផុត?

សឿនៈ ឲ្យវាកន្លងផុតទៅ ផុតទៅហើយ ។

កុសលៈ ហើយកូនដែលធ្លាប់សួរដែរ?

សឿនៈ វាមិនដែលសួរផង វាមិនដែលលឺថាយ៉ាងម៉េចផង ។

កុសលៈ ទៅរៀនគេមិនដែលសួរដែលពីរបបហ្នឹង?

សឿនៈ មិនដឹងអីគេ មិនដឹងគេសួរអត់ មិនដែលបានសួរវា គេសួរដែលហើយ ប៉ុន្តែវាប្រាប់ថាមិនដឹង ឪពុកម្តាយមិនប្រាប់ វាម៉េចដឹង ខ្ញុំលាក់ទុកមិនបាច់ឲ្យកូនចៅដឹងទេ ។

កុសលៈ មានអីបន្ថែមចុងក្រោយទេពូ? ណែនាំឲ្យកូនចៅជំនាន់ក្រោយ លោកពូជាអ្នកតស៊ូម្នាក់ចូលតាំងពី៧៣ ដូចទើបតែចប់២០០៨ ធ្វើសង្គ្រាម ធ្វើយុទ្ធជនហ្នឹង គឺថាកាន់កាំភ្លើងមួយជីវិត ។

សឿនៈ បានខ្ញុំថាខ្ញុំ សំណូមពរសព្វថ្ងៃចង់ឲ្យបានសេចក្តីសុខ និងស្ថេរភាព ឲ្យកម្ពុជាយើងមាន សុខកុំឲ្យស្គាល់ជាតិថាឥឡូវច្បាំងអីទេលោកអើយ ពិបាកណាស់ធ្វើសង្គ្រាមមិនស្រួល ទេសំណូមពរដល់រដ្ឋាភិបាលធ្វើម៉េចឲ្យបានសុខ កែប្រែសង្គម ប្រជាពលរដ្ឋយើង ឲ្យបានដូចសព្វថ្ងៃហ្នឹងទៅ កុំឲ្យមានការឈ្លោះប្រកែក អីចឹងបានខ្ញុំប្តេជ្ញាខ្លួនខ្ញុំបើសិនជាចោរពីខាងក្នុងខ្លួនឯងមិនលូកដៃទេ តែបើចោរពីចម្ងាយ ដូចជាអ្នកជិតខាង រដ្ឋាភិបាលធូរលុងតិះទៀនដែរហ្នឹងខឹងដែរ ពីណាពីណីខ្មែរមកនិយាយសៀម ពិបាក ។

កុសលៈ ខ្ញុំសុំបញ្ចប់ត្រឹមហ្នឹងហើយអរគុណលោកពូច្រើន ហើយខាងសាលាគេជូនមានរបស់តិចតួចមក ពីខាងកូនសិស្ស និស្សិត ជូនជាការដឹងគុណ ។ ជានិមិត្តរូប ជាការអរគុណ ដែលពូបានចូលរួមក្នុងការស្ទាបស្ទង់មតិហ្នឹង ហើយសង្ឃឹមថាលទ្ធផលយើង ធ្វើចប់នៅអន្លង់វែងបន្តទៅធ្វើនៅម៉ាឡៃទៀត ។

សឿនៈ ខ្ញុំក៏សង្ឃឹមថាធ្វើតទៅទៀតបានល្អ សុខសុវត្ថិភាព ។

កុសលៈ បាទ គិតថាយើងខ្មែរវៃខ្មែរវាច្រើនមកហើយ ឈាមបង្ហូរឈាមវាល្មមដល់មួយ យើងរួបរួមគ្នា ផ្សះផ្សារជាតិ អីចឹងបានថាស្មុគស្មាញរឿងបញ្ហាតុលាការ ស្មុគស្មាញបន្តិចធ្វើទៅតាមអន្តរជាតិក៏មិនកើត វាចេះតែតទៅទៀត នឹកឃើញមានការរំដើប រំជួល មានបញ្ហាច្រើន អីចឹងបានថាយើងនិយាយរឿងការផ្សះផ្សារ ដូចលោកពូថា មិញតស៊ូគ្នាទៅវិញទៅមក ដូចខាងលោកពូក៏តស៊ូសំបើមណាស់ ពីខាងក្រៅក៏តស៊ូទំរាំ បានប៉ុណ្ណឹងដែរ មានអ្នកខ្លះពិការជើង ពិការដៃ មើលក្នុងភូមិ ខ្វាក់ភ្នែកក៏មានអីចឹង បានថាខាងក្នុងមិនសូវបានយល់ពីបញ្ហាអស់ហ្នឹងទេ មិនបានស្វែងយល់ទេ ការលំបាកពី ខាងលោកពូ យើងគិតទៅការជួរចត់ តាមខ្ញុំសិក្សាមកឃើញមានទាំងសងខាង កាលណាវៃគ្នាវាឈឺទាំងសងខាងវារបួស ។

សឿនៈ ធម្មតាជះទឹកដាក់គ្នា មិនមែនទទឹកតែម្ខាងទេ ទទឹកទាំង២នាក់ ។

កុសលៈ កាលណាយើងលេងទឹក ជះគ្នាទៅវិញទៅមក វាទទឹកទាំង២នាក់ ។

សឿនៈ ក្មួយឯងជះមក មិនមែនអ៊ំមិនទទឹកឯណា ទទឹកដូចតែគ្នា អ៊ំជះទៅក្មួយឯងក៏ទទឹក ។ អាហ្នឹងធម្មតា រឿងបាចទឹកដាក់គ្នាវាតែងទទឹករាងខ្លួន គ្រាន់តែទទឹកតិច មួយទទឹក ច្រើនតែប៉ុណ្ណឹង ទឹកធ្ងន់ទឹកស្រាលតែប៉ុណ្ណឹង ។ កាលយើងជម្លោះជាមួយថៃហ្នឹងខ្ញុំនឹកឃើញ អញទៅធ្វើទាហានទៀតហើយ អញមិននៅទេ ទៅទៀតហើយ អញនៅមិនបានទេ អាណាក៏មកយ៉ាប់ម៉េះ សន្តិភាពមិនទាន់បានប៉ុន្មានឆ្នាំ ធ្វើស្រែមិនទាន់បានអស់ដីផង មានកើតសង្គ្រាមជាមួយថៃទៀត ប៉ុន្តែខ្ញុំថាអាពួកនេះក៏ខ្ញុំមិនទុកចិត្តប៉ុន្មាន មិនទាន់ទុកចិត្តខ្លួនឯង ប៉ុន្តែបើនិយាយពីឪពុកម្ដាយខ្ញុំគាត់និយាយប្រាប់មកតូចៗ គាត់ថា កូនអើយទៅណាក៏ដោយ រកស៊ីបានរកស៊ីស្រប តំបន់ព្រំដែនកូនឯងកុំនៅឲ្យសោះ សុខសប្បាយៗជាងគេ តែមានទុក្ខក៏ទុក្ខជាងគេដែរ គាត់ធ្លាប់មានបទពិសោធន៍ ក៏មិនដឹងបានគាត់ប្រាប់ដល់ប៉ះខ្លួនឯងវាងអាចម៍ ចំអាចម៍ដដែល មិនចង់នៅទេ ព្រំដែន ចុះយើងធ្វើកងទ័ព ទៅយកដីក្នុងម៉េចបានអ្នកណាគេឲ្យ អាហ្នឹងរបស់គេ មិនមកយកតាមព្រំដែន បើមិនអីចឹងជីវិតម៉េចបានរស់កើត នៅព្រំដែនទៅ មិនដឹងធ្វើម៉េចខ្លួនឯងចាស់វាមិនបញ្ហាទេ នឹកឃើញថាមានសង្គ្រាមវាមិនដែលអាយុ២០០ដែរ យ៉ាងច្រើន១០០ អ្នកខ្លាំងបំផុតហើយនៅ១០០ ។

កុសលៈ ខ្ញុំអ្នកសៀមរាបដែរតា៎ ខ្ញុំអ្នកកំពង់ក្ដី កើតនៅភូមិប្រាសាទ កំពង់ក្ដី ស្រុកសូត្រនិគមមានអីឆ្ងាយណា ។ ហើយឪពុកខ្ញុំពួកវៀតណាមចាប់កាលឆ្នាំ៨៣ គេថាចេញក្បាល ចូលកន្ទុយ ចាប់ជំនាញហ្នឹងឡើងគាត់លីឡឺអស់រលីង ចងស្លាបចេក ។

សឿនៈ ចាប់កាលហ្នឹងមិនមែនធម្មតាទេ សុទ្ធតែប្រកស្បោង ។

កុសលៈ ប្រកស្បោង ហើយនឹងចងមេដាយ២រូតទាញឡើងទៅលើ សន្ទប់ទម្លាក់មកជះទឹក ហើយខ្ញុំចាំព្រឹត្តិការណ៍ហ្នឹងរហូត ខ្ញុំកាលហ្នឹងអាយុប្រហែលជា១៣ឆ្នាំ បានខ្ញុំចាំ មួយអាទិត្យ ឲ្យម្ដាយខ្ញុំនាំទៅមើល ហើយពួកវៀតណាមបណ្ដើរចងស្លាបសេកគាត់មក ភ្លង់ ពីក្រោយមកពេលហ្នឹងចាំវ៉ៃឡើងបែកមុខអស់ហើយ ហើយចាំរហូត ពេលហ្នឹងខ្ញុំចេះ តែគិតថាវាដូរចត់ អ្វីដែលខ្ញុំចាំមក ចាំបានប៉ុណ្ណឹង អីចឹងបានថាសង្គ្រាមពេលហ្នឹងហិនហោច ឆ្លងកាត់របបពាឆ្នាំផ្សេង ដល់បន្ទាប់មកទៀត៨២-៨៣នេះ ។

សឿនៈ នៅតែមានរឿង ។

កុសលៈ ខាងនេះដាច់ដៃដាច់ជើង ខាងនោះមានពួកវៀតណាមធ្វើបាប យើងថាឲ្យមានតែវ៉ៃគ្នាខ្មែរ យើងឈឺទាំងសងខាង មិនមែនតែខាងក្រៅទេ ខាងក្នុងក៏អីចឹងដែរ ដល់ថ្នាក់ចៅហ្វាយ

ស្រុក គេចាប់យកទៅធ្វើបាបដល់លីឡឹងដល់សព្វថ្ងៃមានធ្វើអីកើតសព្វថ្ងៃ អាយុគាត់ប្រហែលជិណាលពូដែរ បង១-២ឆ្នាំ គាត់ក៏អ្នកតស៊ូម្នាក់ដែរ ដើម្បីជាតិ ។

សឿន: ចុះ ពុយ រឿង យើងមិនចៅហ្វាយស្រុកបន្ទាយស្រី សព្វថ្ងៃហ្នឹង ដល់គាត់ឆ្លាតទៅបានគេប ។

កុសល: ពូរឿង ហ្នឹង?

សឿន: បាទ ។

កុសល: ស្គាល់ពុកខ្ញុំ ស្គាល់គ្នា ហៅអាខុមៗ ហៅសុទ្ធតែអីចឹង ហៅពុកខ្ញុំសុទ្ធតែអាទៅវិញទៅ មកស្គាល់គ្នា ពេលទៅប្រជុំរៀនជាមួយគ្នា ពុកខ្ញុំគេវ៉ៃហើយលែងដឹងអីគាត់លែងចង់ តែម្តងគាត់ឈប់តែម្តង គាត់បាក់ស្បាត ។

សឿន: ទារុណកម្មវាធ្ងន់ធ្ងរពេក ។

កុសល: បាទ ធ្ងន់ធ្ងរពេក អីចឹងសរុបមកឈឺទាំងសងខាង ពេលយើងឈ្លោះគ្នា ដូចលោកពូថាម៉ិញអីចឹង ។

សឿន: អត់មានឈឺបរទេសណា ឈឺខ្មែរហ្នឹង ទាំងសងខាង ។

កុសល: ជះទឹកប្រឡាក់ទាំងសងខាងមែន ជះភក់ប្រឡាក់ភក់ ជះឈាមប្រឡាក់ឈាមទាំងសងខាង ។

សឿន: សរុបលទ្ធផលទៅអត់មានបរទេសសោះ សុទ្ធតែខ្មែរ ។

កុសល: កើតក្បែរៗគ្នា ក្បែរភូមិ-ឃុំជាមួយ ។ អីចឹងអរគុណលោកពូហើយ ខ្ញុំទៅខាងនោះបន្តិច ។

សឿន: អត់អីទេ

កុសល: អរគុណហើយពូ ។

«ចប់»